KH/2007/ED/MNL/44
Phnom Penh, September 2007
Original: English

# ការអប់រំ

## នៅក្នុងពិភពលោកមួយ ដែលប្រើពហុភាសា

_UNESCO Education Position Paper_

UNESCO

Published in 2003 by the United Nations
Educational, Scientific and Cultural Organization.
7, place de Fontenoy - 75007 Paris (France)
www.unesco.org/education

© UNESCO 2003
Printed in France
(ED-2003/WS/2)

# ការអប់រំ

## នៅក្នុងពិភពលោកមួយ ដែលប្រើពហុភាសា

_UNESCO
Education
Position
Paper_
2003

# មាតិកាអត្ថបទ


លំនាំដើម ៨

ជំពូក១ : បរិបទប្រើច្រើនភាសា : កាតព្វកិច្ចដែល
ប្រព័ន្ធអប់រំ ត្រូវបំពេញចំពោះមុខ ១០

ជំពូក២ : ក្របខ័ណ្ឌសកម្មភាពរួម សម្រាប់ការប្រើភាសា
និងការអប់រំ ២០

ក. ច្បាប់កំណត់តាមស្តង់ដា
អង្គការសហប្រជាជាតិ ២២

ខ. សេចក្តីថ្លែងការណ៍ និង
អនុសញ្ញារបស់អង្គការយូណេស្កូ ២៤

គ. លទ្ធផលទទួលបានពីសន្និសីទ
អន្តរជាតិនានា ២៥

ជំពូក៣ : សេចក្តីណែនាំរបស់អង្គការ យូណេស្កូ
ស្តីពីភាសា និង ការអប់រំ ២៨

កំណត់សម្គាល់ ៣៥

EDITORIAL COORDINATION: LINDA KING

ACKNOWLEDGEMENTS
MANY PEOPLE HAVE SHAPED THIS POSITION PAPER WITH COMMENTS AND CONTRIBUTIONS.
IN PARTICULAR UNESCO WOULD LIKE TO THANK:
AYO BAMGBOSE, ANNIE BRISSET, LOUIS-JEAN CALVET, ERNESTO COUDER,
DENIS CUNNINGHAM, TARCISIO DELLA SENTA, NADINE DUTCHER, JUAN CARLOS GODENZZI,
MARIA CARME JUNYENT, IRINA KHALEEVA, LACHMAN M. KHUBCHANDANI, DON LONG,
FÈLIX MARTÍ, MIRIAN MASAQUIZA, ELITE OLSTHAIN, HENRIETTE RASSMUSSEN,
DÓNALL Ó RIAGÁIN, SUZANNE ROMAINE, ADAMA SAMASSÉKOU, TOVE SKUTNABB-KANGAS.
SPECIAL THANKS ARE DUE TO DOERTHE BUEHMANN FOR ASSISTANCE IN BACKGROUND RESEARCH.

# កថាមុខ

ការអប់រំសម្រាប់ទាំងអស់គ្នា មានន័យថា ជាការអប់រំប្រកបដោយគុណភាពសម្រាប់មនុស្សគ្រប់ៗរូប។ នៅក្នុងពិភពលោកបច្ចុប្បន្ន ការអប់រំសម្រាប់ទាំងអស់គ្នាមានន័យថា ការអប់រំត្រូវពិចារណាគ្រប់សមាសភាព និងគ្រប់បរិការណ៍នៃវប្បធម៌ និងភាសា ដែលមាននៅក្នុងសង្គមបច្ចុប្បន្ន។ កត្តានេះ បានដាក់បន្ទុកមួយទៅលើអ្នកតាក់តែងគោលនយោបាយអោយពិចារណា អំពីសមាសភាព និងសមត្ថភាពរបស់ប្រជាពលរដ្ឋនៅក្នុងប្រទេស ហើយក្នុងពេលជាមួយគ្នា ត្រូវធានាការពារសិទ្ធិ របស់ប្រជាជនភាគតិច និងជនជាតិដើមភាគតិចដែលប្រើ ភាសា និងវប្បធម៌ខុសពីក្រុមប្រជាជនភាគច្រើន។ សង្គមបច្ចុប្បន្ន ដែលមានការរីកចម្រើន ផ្នែកសេដ្ឋកិច្ច អាស្រ័យលើសកលភាវូបនីយកម្ម កាន់តែត្រូវការចំណេះដឹងផ្នែកភាសាថែមទៀត។ កត្តានេះ កាន់តែដាក់បន្ទុកធ្ងន់ធ្ងរ និងស្មុគ្រស្មាញថែមទៀត។ អង្គការយូណេស្កូ បានប្តេជ្ញា និងពុះពារយ៉ាងធំធេង ដើម្បីលើកកំពស់តម្លៃនៃនានាភាព និងពហុភាពនៃវប្បធម៌ ហើយធានាថែរក្សានិរន្តរភាព អោយបានថែមទៀតផង។ ការអប់រំ ក៏ជាមធ្យោបាយមួយ និងជាការ បង្ហាញ អំពីនានាភាពនៃ វប្បធម៌ផងដែរ។ លើសពីនេះទៅទៀត ការស្រាវជ្រាវបានបង្ហាញថា អ្នករៀនពិតជារៀនបានល្អប្រសើរ និងពូកែ ប្រសិនបើរៀនជាមាតុភាសាពីដំបូងអោយចេះ ហើយបំពេញបន្ថែមដោយប្រើ វិធីសាស្ត្រអប់រំប្រើពីរភាសា។

ឯកសារស្តីពីការអប់រំនៅក្នុងពិភពលោកមួយ ដែលប្រើពហុភាសា មានគោលបំណងសំដៅពន្យល់អោយច្បាស់អំពីបញ្ញត្តិ និងបញ្ហាគន្លឹះមួយចំនួន ទាក់ទងនឹងគោលគំនិតពន្យល់ខាងលើ ហើយមានគោលបំណងបង្ហាញអំពីខ្លឹមសាររបស់សេចក្តីថ្លែងការណ៍ និងអនុសាសន៍ ដែលបានប្រើជាឯកសារជំនួយស្មារតី ទាក់ទងនឹងបញ្ហាភាសា និងការអប់រំក្នុងទម្រង់មួយ ដែលងាយយល់ និងងាយប្រើប្រាស់។ ការពន្យល់នេះ បានតាក់តែងជាសេចក្តីណែនាំ និងគោលការណ៍ទូទៅរបស់អង្គការយូណេស្កូ។ សេចក្តីណែនាំ និងគោលការណ៍ទូទៅទាំងនេះ អាចចាត់ទុកដូចជា ផ្លែឈើបង្អែមលាងមាត់ សម្រាប់ការពិភាក្សានៅក្នុងកិច្ចប្រជុំអន្តរជាតិជាច្រើន និងនៅក្នុងសន្និសីទរបស់អង្គការសហប្រជាជាតិ និងរបស់អង្គការយូណេស្កូ ហើយអាចចាត់ទុកជាជំនាញឯកទេសមួយច្បាស់លាស់សម្រាប់តាក់តែងគោលនយោបាយភាសា និងការអប់រំ។ កិច្ចប្រជុំក្រុមអ្នកជំនាញការមួយក្រុម បានរៀបចំឡើងនៅទីក្រុង ប៉ារីសកាលពីខែកញ្ញា ឆ្នាំ ២០០២* បានកែលំអ និងពង្រីកខ្លឹមសាររបស់ឯកសារដើម ដែលពិពណ៌នាយ៉ាងច្រើនអំពី តួនាទីរបស់អង្គការយូណេស្កូនៅក្នុងវិស័យភាសា និងការអប់រំនេះ។

យើងសង្ឃឹមថា ឯកសារនេះ នឹងជួយជាស្មារតីដល់រដ្ឋជាសមាជិក នៅទូទាំងសកលលោក ពិចារណាអំពីបញ្ហាទាក់ទងនឹងភាសា និងការអប់រំ ហើយយើងសូមអំពាវនាវអោយរដ្ឋទាំងអស់បកប្រែឯកសារនេះ ទៅជាភាសាជាតិជាច្រើន តាមដែលអាចធ្វើបាន។

* ជំនួយគាំទ្រផ្នែកហិរញ្ញវត្ថុសម្រាប់កិច្ចប្រជុំនេះ ទទួលបានពីគណកម្មការជាតិហ្វាំងឡង់ សម្រាប់អង្គការយូណេស្កូ កំពុងទទួលបានការកោតសរសើរជាបណ្តើរៗ។

# លំនាំដើម

អង្គការយូណេស្កូមានតួនាទីដ៏សំខាន់មួយ ក្នុងការផ្តល់ក្របខ័ណ្ឌសកម្មភាពអន្តរជាតិសម្រាប់ការតាក់តែង គោលនយោបាយអប់រំ និងការអនុវត្តគោលនយោបាយអប់រំ ដើម្បីដោះស្រាយបញ្ហាគន្លឹះៗ និងស្មុគ្រស្មាញនៅក្នុងវិស័យអប់រំ។ ជាពិសេស ជម្រើសនៃការប្រើភាសាក្នុងការរៀន និងបង្រៀន នៅក្នុងប្រព័ន្ធអប់រំ គឺជាលក្ខខណ្ឌ ឬជាក្តីកង្វល់មួយ ហើយជម្រើសនេះគឺជាបញ្ហាដែលមានគំនិតជុំយគ្នាច្រើន ហើយពិបាកនឹងសម្រេចថា ត្រូវជ្រើសរើសយកជំហរមួយណា។ ចម្ងល់ទាក់ទងនឹងអត្តសញ្ញាណជាតិ និងអំណាចមានអន្តរទំនាក់ទំនងស្អិតរមួតទៅនឹងការប្រើប្រាស់ភាសានៅក្នុងថ្នាក់រៀន។ ភាសា មានជីវិតរស់រវើក ហើយមានបំរែបំរួល និងផ្លាស់ប្តូរឥតឈប់ ដែលមានឥទ្ធិពលទៅលើការប្រាស្រ័យទាក់ទងគ្នានៅក្នុងសង្គមផ្សេងៗគ្នា។ អ្នកតាក់តែងគោលនយោបាយអប់រំមានការលំបាកក្នុងការសម្រេចចិត្តទាក់ទងនឹងការប្រើប្រាស់ភាសា ការរៀនសូត្រ និងអំពីកម្មវិធីសិក្សានៅក្នុងសាលា ព្រោះការសម្រេចចិត្តនេះ អាចជាន់គ្នា រវាងបច្ចេកទេស និងនយោបាយ។ ប្រសិនបើមានការពេញនិយមក្នុងការប្រើមាតុភាសា (ភាសាទីមួយ) នៅក្នុងការរៀន និងបង្រៀន ចាំបាច់ត្រូវថ្លឹងថ្លែងអំពីសមត្ថភាពរបស់អ្នករៀន ក្នុងការប្រើប្រាស់ភាសាក្នុងស្រុក ក្នុងការរៀនសូត្រ និងផ្តល់លទ្ធភាព និងឱកាសអោយអ្នករៀន មានសមត្ថភាពប្រើភាសាសកល ក្នុងការប្រាស្រ័យទាក់ទង តាមរយៈប្រព័ន្ធអប់រំផងដែរ។ គោលបំណងរបស់ឯកសារនេះ គឺសំដៅពិចារណាអំពីបញ្ហាមួយចំនួន ទាក់ទងនឹងភាសា និងការអប់រំ ហើយសំដៅផ្តល់សេចក្តីណែនាំ និងគោលការណ៍ពាក់ព័ន្ធមួយចំនួន។ ដើម្បីសម្រេចគោលបំណងនេះ យើងត្រូវយល់ច្បាស់ អំពីគោលនយោបាយភាសាប្រើប្រាស់នៅក្នុង វិស័យអប់រំ ជាពិសេសនៅក្នុងបរិបទនៃការអប់រំសម្រាប់ទាំងអស់គ្នា និងស្របតាមគោលដៅក្រុងដាកា ដែលធានាថា នៅមុន ឬត្រឹមឆ្នាំ ២០១៥ កុមារទាំងអស់ នឹងមានឱកាសទទួលបានការអប់រំបឋមសិក្សា ប្រកបដោយគុណភាពគ្រប់ៗគ្នា ហើយធានាថា នៅមុន ឬត្រឹមឆ្នាំ ២០១៥ អក្ខរកម្មមនុស្សចាស់ នឹងកើនបាន ៥០ ភាគរយ។

នៅឆ្នាំ ១៩៥៣ អង្គការយូណេស្កូ បានបោះពុម្ពរបាយការណ៍ជំនាញមួយ ស្តីពីការប្រើប្រាស់ភាសាក្នុងស្រុក នៅក្នុងប្រព័ន្ធអប់រំ ហើយឯកសារនេះ នៅតែមានតួនាទីសំខាន់ មានអ្នកដកស្រង់ខ្លឹមសារមកពីឯកសារនោះយ៉ាងច្រើន អោយតែនិយាយទាក់ទងនឹងបញ្ហាភាសានៅក្នុងប្រព័ន្ធអប់រំ។ កាលពី ៥០ ឆ្នាំមុន មានការប្រែប្រួលច្រើន ដែលជម្រុញអោយមានការកែប្រែនយោបាយ ឈានទៅបង្កើតគោលនយោបាយភាសាថ្មី ជាពិសេសនៅតាមបណ្តាប្រទេសរស់ក្រោមអាណានិគម និងប្រទេសទទួលបានឯករាជ្យថ្មីៗ។ កាលនោះ មានភាសារាប់រយនៅទូទាំងសកលលោក ត្រូវរលាយបាត់រូប ហើយភាសាជាច្រើនទៀត ត្រូវប្រឈមនឹងគ្រោះថ្នាក់នៃការបាត់បង់ទៀត។ ដោយសារចលនានៃការផ្លាស់លំនៅអន្តោប្រវេសន៍ មានភាពខ្លាំងក្លា ទើបប្រទេសជាច្រើន និងទ្វីបជាច្រើនទទួលបានភាសាថ្មី និងភាសាជាច្រើន។ បច្ចុប្បន្ន ប្រព័ន្ធអ៊ីនធឺណែត ក៏មានឥទ្ធិពលខ្លាំងក្លាទៅលើការប្រើប្រាស់ភាសាក្នុងការប្រាស្រ័យទំនាក់ទំនង និងសម្រាប់រៀនសូត្រផងដែរ។ សកលភាវូបនីយកម្ម

ដែលចេះតែរីកធំទៅៗ ក៏បង្ខំអោយប្រទេសតូចៗ តំបន់តូចៗ ពឹងពាក់លើភាសាផងដែរ។ ដូច្នេះ ពេលវេលា បានមកដល់ហើយ អង្គការយូណេស្កូ ត្រូវពិចារណាឡើងវិញ អំពីតួនាទីរបស់ខ្លួននៅក្នុង ការប្រើប្រាស់ភាសា និងនៅក្នុងប្រព័ន្ធអប់រំ។

ឯកសារនេះ ចែកចេញជាបីផ្នែកធំៗ : ផ្នែកទីមួយ បង្ហាញអំពីបញ្ញត្តិគន្លឹះ ដែលត្រូវប្រើ ទាក់ទងនឹងការអប់រំ ដោយប្រើច្រើនភាសា។ គោលបំណងរបស់ផ្នែកនេះ គឺសំដៅបញ្ជាក់ន័យ និង វាក្យស័ព្ទ ដែលប្រើនៅក្នុងភាសា និងការអប់រំអោយច្បាស់។ ផ្នែកទីពីរ ធ្វើសំយោគក្របខ័ណ្ឌ សកម្មភាពសម្រាប់ភាសា និងការអប់រំ ដោយ ទីមួយសំអាងជាធំទៅលើការវិភាគច្បាប់នានារបស់ អង្គការសហប្រជាជាតិ ទីពីរសំអាងទៅលើការពិភាក្សាអំពីអនុសញ្ញារបស់អង្គការយូណេស្កូ និង សេចក្តីថ្លែងការណ៍សំខាន់ៗ ដើម្បីធ្វើជាឯកសារជំនួយស្មារតី សម្រាប់សិក្សាអំពីបញ្ហាភាសា និង វប្បធម៌ ហើយទីបី សំអាងទៅលើលទ្ធផល និងអនុសាសន៍ ទទួលបានពីសន្និសីទអន្តរជាតិនានា ទាក់ទងដោយផ្ទាល់ និងដោយប្រយោលជាមួយនឹងបញ្ហាភាសា និងការអប់រំ។ ផ្នែកទីបី វិភាគ និង ធ្វើសំយោគ ទៅលើឯកសារពិភាក្សា និងឯកសារកិច្ចព្រមព្រៀង ស្តីពីបញ្ហាភាសា ដែលបានអនុម័ត រួមគ្នា ដោយអង្គការសហប្រជាជាតិ និងអង្គការយូណេស្កូ។ លទ្ធផលទទួលបានពីការវិភាគ និង សំយោគនេះ បានដាក់ចេញជាសេចក្តីណែនាំ និងគោលការណ៍ជាក់លាក់ ដែលមានគោលបំណង ផ្សព្វផ្សាយអោយបានទូលំទូលាយ អំពីគោលជំហររបស់អង្គការយូណេស្កូ និងផ្សព្វផ្សាយឯកសារនេះ អោយបានច្រើន និងងាយស្រួលប្រើ។

# បរិបទប្រើេ
# កាតព្វកិច្ចដែ
# ត្រូវបំពេ

# ច្រើនភាសា ៖ លប្រព័ន្ធអប់រំ ញចំពោះមុខ

ការអប់រំនៅប្រទេសជាច្រើននៅលើពិភពលោក ប្រើប្រាស់ពហុភាសា។ សង្គមដែលប្រើប្រាស់ពហុភាសា បានអភិវឌ្ឍ ក្រមសីលធម៌ និងតម្លៃខាងភាសា ដែលធានាអោយមានតុល្យភាព និងការគោរពភាសាផ្សេងគ្នា នៅក្នុងជីវភាពប្រចាំថ្ងៃ។ តាមទស្សនៈ និងការជាក់ស្តែងកើតឡើងនៅក្នុងសង្គមប្រភេទនេះ ហើយយោងតាមជីវភាពពិតនៅក្នុងសហគមន៍ នៅក្នុងសង្គមបែបនេះ ពហុភាសា គឺជាផ្លូវជីវិតមួយ មិនមែនជាបញ្ហាពិបាកដោះស្រាយនោះទេ។ កាតព្វកិច្ចចំបង ដែលប្រព័ន្ធអប់រំត្រូវបំពេញគឺ សម្របខ្លួនទៅតាមជីវភាពជាក់ស្តែង ដ៏ស្មុគ្រស្មាញនេះ ហើយផ្តល់ការអប់រំប្រកបដោយគុណភាព ដែលបំរើតម្រូវការជាក់ស្តែងរបស់អ្នករៀន ហើយក៏ត្រូវថ្លឹងថ្លែងកត្តាទាំងនេះ ជាមួយនឹងតម្រូវការសង្គម វប្បធម៌ និងនយោបាយផងដែរ។ ប្រសិនបើ ដំណោះស្រាយរួម សម្រាប់សង្គមប្រើពហុភាសា មានលក្ខណៈសាមញ្ញ តាមបែបរដ្ឋបាល និងគ្រប់គ្រង ដំណោះស្រាយរួមនោះប្រហែលជាមិនបង្កគ្រោះថ្នាក់ ដល់លទ្ធផលរៀនសូត្រ ហើយក៏មិនបង្កការភ័យខ្លាចអំពីការបាត់បង់នានាភាពនៃភាសា និងវប្បធម៌នៅក្នុងសង្គមទេ។ ផ្នែកនេះ ពិភាក្សាអំពីបញ្ហាមូលដ្ឋានមួយចំនួន ដែលទាក់ទងច្រើនជាមួយនឹងការផ្តល់ការអប់រំនៅក្នុងស្ថានភាពនៃការប្រើប្រាស់ពហុភាសា។

## → នានាភាព និងពហុភាពនៃភាសា

*នានាភាពនៃភាសា និយាយអំពីការកកើតឡើងនៃភាសាច្រើន ដែលមានអ្នកនិយាយច្រើននៅលើពិភពលោក ដែលតាមការស្មាន មានភាសាពី ៦០០០ ទៅ ៧០០០ ភាសា។ ការថែរក្សានានាភាពនៃភាសានេះអោយបាននៅថ្ងៃនេះ គឺជាកាតព្វកិច្ចចំបងមួយក្នុងចំណោមកាតព្វកិច្ចចំបងនិងបន្ទាន់ជាច្រើន ដែលពិភពលោកកំពុងប្រឈមមុខដោះស្រាយ។ ការស្មាននៃចំនួនភាសានេះពន្យល់ថា ក្នុងចំណោមភាសាទាំងអស់នេះ មានចំនួនពាក់កណ្តាលកំពុងប្រឈមនឹងគ្រោះថ្នាក់នៃការបាត់បង់ក្នុងពេល អនាគតដ៏ខ្លីខាងមុខនេះ[1]។ ប្រសិនបើ ប្រទេសមួយចំនួនរួមដៃគ្នា តាមក្រិត្យក្រមភាសា ដូចជាប្រទេស អៃស៍ឡែន ប្រទេស និងតំបន់ជាច្រើន មាននានាភាពនៃភាសាដ៏សំបូរបែប ដូចជា ប្រទេសឥណ្ឌូនេស៊ី មាន ៧០០ ភាសា ហើយប្រទេស ប៉ាពួញូហ្គេនី មានជាង ៨០០ ភាសា[2]។ ដូច្នេះ យើងអាចយល់បានថា របាយនានាភាពនៃភាសា មានភាពមិនស្មើគ្នាប្រាកដមែន។ ភាសាជាង ៧០ ភាគរយនៅពិភពលោក មាននៅប្រទេស ២០ ប៉ុណ្ណោះ ដែលមួយចំនួនជាប្រទេសក្រីក្របំផុត។ ជាទូទៅ បរិបទពីរភាសា ឬច្រើនភាសា ដែលមានន័យថា មានប្រជាជនច្រើនក្រុមនិយាយភាសាខុសៗគ្នា រស់នៅប្រទេសតែមួយ គឺជាក្រិត្យក្រមសង្គម មិនមែនជារឿងចម្លែកនៅលើពិភពលោកទេ ទាំងនៅប្រទេសក្នុងតំបន់ភាគ ខាងត្បូង និងភាគខាងជើង។* **ពីរភាសា និងច្រើនភាសា** *គឺមានន័យថា ប្រើប្រាស់ភាសាច្រើនជាងមួយភាសា នៅក្នុងជីវភាពប្រចាំថ្ងៃ នឹងក្លាយទៅជារឿងធម្មតាក្នុងបរិបទសង្គមជាមិនខាន។*

បរិបទនៃនានាភាពភាសា មានច្រើនសណ្ឋាន។ និយាយជារួម បរិបទទាំងនេះទាក់ទងនឹងស្ថានភាពនៃនានាភាពប្រពៃណី នៅក្នុងសង្គម ដែលមានភាសាច្រើន ឬរាប់រយភាសា ត្រូវបាននិយាយនៅក្នុងតំបន់ ក្នុងរយៈពេលមួយយ៉ាងយូរ ឬទាក់ទងនឹងការអភិវឌ្ឍ (ជាពិសេសនៅទីប្រជុំជន)។ លទ្ធផលនៃការប្រើច្រើនភាសានេះ កើតឡើងដោយសារចលនានៃបំលាស់លំនៅអន្តោប្រវេសន៍។ នៅតាមសាលាមួយចំនួននៅទីក្រុង អាចមានសិស្ស ដែលនិយាយភាសាផ្សេងគ្នាពី៣០ ទៅ ៤០ ភាសា។ ក្នុងករណីទាំងអស់នេះ ត្រូវពិចារណាអំពីតម្រូវការរៀនសូត្ររបស់សិស្សទាក់ទងនឹងភាសា ដែលប្រើប្រាស់នៅតាមគ្រួសារ និងភាសាប្រើប្រាស់នៅតាមសាលា។

## ➜ ភាសាប្រជាជនភាគតិច និង ភាសាប្រជាជនភាគច្រើន

បញ្ញត្តិនៃនានាភាពភាសា មានទំនាក់ទំនងគ្នា ហើយជាធម្មតា កំណត់ដោយព្រំប្រទល់ប្រទេស ទើបធ្វើអោយភាសាមួយចំនួនមានឋានៈ ជាភាសាប្រជាជនភាគច្រើន ហើយភាសាផ្សេងទៀត មានឋានៈជាភាសាប្រជាជនភាគតិច ស្របតាមបរិបទប្រទេសនីមួយៗ។ ឧទាហរណ៍ ភាសាចិន ម៉ង់ដារិន ជាភាសាមួយក្នុងចំណោមភាសា ដែលមានអ្នកនិយាយច្រើនជាងគេបំផុតនៅលើពិភពលោក ដែលមានប្រជាជនជិត ៩០០ លាននាក់និយាយ ហើយភាសានេះ ជា**ភាសាប្រជាជនភាគច្រើន** នៅប្រទេសចិន ប៉ុន្តែនៅប្រទេសផ្សេង ដែលមានជនជាតិចិនតិចប្រើប្រាស់ភាសាចិន និងប្រកាន់ទំនៀមទម្លាប់ចិន នោះភាសាចិន ម៉ង់ដារិន នឹងក្លាយ**ជាភាសាប្រជាជនភាគតិច**របស់ប្រទេស ដែលមានប្រជាជនច្រើនលើសលប់ជនជាតិចិន។ ស្រដៀងគ្នាដែរ ភាសាប្រជាជនភាគតិចនៅប្រទេសដ៏ធំមួយ ក៏អាចចាត់ទុកជាភាសាប្រជាជនភាគច្រើន នៅប្រទេសតូចបានដែរ។ ប៉ុន្តែ ភាសាភាគច្រើនបំផុតនៅលើពិភពលោក គិតទាំងភាសាសញ្ញាសម្រាប់មនុស្សថ្លង់ និងអក្សរសម្រាប់ មនុស្សខ្វាក់ គឺជាភាសាប្រជាជនភាគតិចនៅតាមប្រទេសដែរ។ ពាក្យ "ប្រជាជនភាគតិច" មានន័យ មិនច្បាស់លាស់ ហើយអាចបកប្រែ និងបកស្រាយខុសគ្នាក្នុងបរិបទផ្សេងគ្នា ព្រោះពាក្យប្រជាជន ភាគតិច អាចមានន័យពីរ សម្រាប់រាប់ចំនួន និងសម្រាប់សង្គម ឬនយោបាយ។ ក្នុងករណីខ្លះ ពាក្យប្រជាជនភាគតិចនេះ អាចប្រើសម្រាប់មនុស្សសាមញ្ញ ឬក្រុមប្រជាជនធម្មតា ដែលមានចំនួនតិចជាងក្រុមមនុស្សដទៃ រស់នៅក្នុងរបបសង្គម និងនយោបាយដូចគ្នា។

## ➜ ភាសាផ្លូវការ និងភាសាជាតិ

ទោះបីជាមានប្រទេសច្រើនជាង ២០ មានភាសាច្រើនជាងមួយ ជា**ភាសាផ្លូវការ** (ឧទាហរណ៍ ប្រទេសឥណ្ឌាតែមួយ មានភាសាផ្លូវការចំនួន ១៩ ចំណែកអាព្រិចខាងត្បូងមានភាសាផ្លូវការចំនួន ១១) ក៏ប្រទេសភាគច្រើននៅលើពិភពលោក មានភាសាតែមួយប្រើប្រាស់ ដែលទទួលស្គាល់ជា

ផ្លូវការ សម្រាប់ទាំងភាសាផ្លូវការនៅក្នុងរដ្ឋាភិបាល និងភាសាច្បាប់។ ក្នុងន័យនេះ មិនមែននិយាយថា ប្រទេសទាំងនោះមិនមែនជាសង្គមប្រើពីរភាសា ឬច្រើនភាសានោះទេ ប៉ុន្តែប្រហែលជាមានភាសាច្រើនប្រើប្រាស់នៅក្នុងប្រទេសនោះ ដែលមិនបានទទួលស្គាល់ស្របច្បាប់ជាភាសាផ្លូវការនៅក្នុងប្រទេស។ នៅប្រទេសជាច្រើន ដែលធ្លាប់រស់នៅក្រោមនឹមអាណានិគម ភាសាផ្លូវការភាគច្រើនជាភាសារបស់ប្រទេសអាណានិគម។ លើសពីភាសាផ្លូវការទៀត ប្រទេសជាច្រើនទទួលស្គាល់ភាសាជាតិ ដែលប្រើជាផ្លូវការ និងប្រើដោយកាតព្វកិច្ចនៅក្នុងប្រព័ន្ធអប់រំ។ ជម្រើសភាសាប្រើប្រាស់នៅក្នុងប្រព័ន្ធអប់រំ មានអំណាច និងផ្តល់កិត្យានុភាព ដល់ភាសានោះ តាមរយៈការប្រើប្រាស់ភាសានោះនៅក្នុងការរៀន និងបង្រៀននៅក្នុងប្រព័ន្ធអប់រំ។ មិនត្រឹមតែទទួលបាននិមិត្តសញ្ញាមួយ សម្រាប់បង្ហាញ អំពីស្ថានភាព និងរូបភាពនៃភាសានោះទេ ប៉ុន្តែភាសានោះ ទទួលបានតម្លៃរួមមួយ ហើយបង្ហាញរូបរាងមួយអោយពិភពលោកមើលឃើញថែមទៀតផង។

## ➞ ភាសាសម្រាប់រៀន និងបង្រៀន

**ភាសាសម្រាប់រៀន និងបង្រៀន** ទាំងក្នុង និងក្រៅសាលា និយាយអំពីភាសាប្រើប្រាស់នៅក្នុងកម្មវិធីសិក្សាមូលដ្ឋានរបស់ប្រព័ន្ធអប់រំ។ ជម្រើសភាសា ឬភាសាប្រើប្រាស់សម្រាប់រៀន និងបង្រៀន (គោលនយោបាយអប់រំ គួរអនុម័តអោយប្រើប្រាស់ច្រើនភាសានៅក្នុងការរៀន និងបង្រៀន) គឺជាកាតព្វកិច្ចមួយ ដែលត្រូវបំពេញ ដើម្បីធានាអោយមាន គុណភាពអប់រំ។ ប្រទេសមួយចំនួនមានបំណងប្រើភាសាតែមួយនៅក្នុងការរៀន និងបង្រៀន ដែលជាភាសាផ្លូវការ ឬភាសាប្រជាជនភាគច្រើន ប្រទេសផ្សេងទៀត បានជ្រើសរើសយុទ្ធសាស្ត្រអប់រំ ដែលផ្តល់តួនាទីសំខាន់មួយដល់ភាសាក្នុងស្រុក ឬភាសាជាតិ នៅក្នុងការរៀនសូត្រ។ អ្នកនិយាយមាតុភាសា ដែលខុសពីភាសាជាតិ ឬភាសាក្នុងស្រុក តែងបាត់បង់ឱកាសយ៉ាងច្រើននៅក្នុងប្រព័ន្ធអប់រំ ស្រដៀងគ្នានឹងការបាត់បង់ឱកាសទទួលបានការរៀនសូត្រ ជាភាសាបរទេសផ្លូវការនៅក្នុងប្រទេសផងដែរ។

## ➞ ការរៀន និងបង្រៀន ដោយប្រើមាតុភាសា

ការរៀន និងបង្រៀន ដោយប្រើ **មាតុភាសា** និយាយអំពីការប្រើប្រាស់មាតុភាសារបស់អ្នករៀនក្នុងកម្រិតអប្បបរមានៃការរៀន និងបង្រៀន។ លើសពីនេះទៅទៀត ការរៀន និងបង្រៀនដោយប្រើមាតុភាសា អាចនិយាយអំពី ការចាត់ទុកមាតុភាសាជាមុខវិជ្ជារៀនមួយនៅក្នុងកម្មវិធី សិក្សា។ ការរៀន និងបង្រៀន ដោយប្រើមាតុភាសា មានតួនាទីមួយរួមចំណែកក្នុងការលើកកំពស់គុណភាពអប់រំ ជាពិសេសនៅក្នុងវ័យកុមារតូច។ តាមទស្សនៈរបស់អ្នកឯកទេស ការរៀន និងបង្រៀន ដោយប្រើមាតុភាសា ជាមុខវិជ្ជាបង្រៀនមួយ និងបង្រៀនមុខវិជ្ជាដោយប្រើមាតុភាសា។

ពាក្យ"មាតុភាសា" ទោះបីជាមានន័យប្រើប្រាស់ទូលំទូលាយក៏ដោយ ក៏អាចនិយាយអំពីស្ថានភាពខុសៗគ្នារបស់ភាសាដែរ។ និយមន័យនៃមាតុភាសាត្រូវមានកត្តាសំខាន់ៗដូចជា : ភាសាដែលមនុស្សម្នាក់បានរៀនពីដំបូង ភាសាដែលមនុស្សម្នាក់ប្រើតាំងពីកំណើត ភាសាដែលមនុស្សម្នាក់ចេះច្បាស់ជាងគេបំផុត និងជាភាសាដែលមនុស្សម្នាក់ប្រើប្រាស់ញឹកញាប់ជាងគេបំផុត។ "មាតុភាសា" អាចមានន័យថា ជាភាសា "ទីមួយ" ឬ ភាសា"ដំបូង" របស់អ្នកប្រើ។ ពាក្យ "មាតុភាសា" ប្រើជាច្រើននៅក្នុងគោលនយោបាយ និងនៅក្នុងឯកសារសំខាន់ៗស្តីពីបញ្ហាអប់រំ។ ពាក្យនេះ ប្រើជាប់នៅក្នុងឯកសារនេះ ដោយសារហេតុផលពន្យល់ខាងលើនេះ ទោះបីជាមានការកត់សម្គាល់ថា ការប្រើប្រាស់ពាក្យ "មាតុភាសា មិនបែងចែក ឬរើសអើងនៅក្នុងធម្មជាតិនៃភាសា ប្រើដោយម្ចាស់ភាសាក៏ដោយ ដែលមានលក្ខណៈខុសគ្នាពីភាសាអ្នកប្រើនៅតំបន់ដាច់ស្រយាល និងភាសាប្រើនៅក្នុងតំបន់ទីប្រជុំជន ប្រើជាមាតុភាសាចេញពីសាលា។ បទពិសោធដំបូងរបស់កុមារមួយនាក់ ក្នុងការនិយាយមាតុភាសា មិនចាំបាច់ត្រឹមត្រូវតាមលក្ខណៈមាតុភាសា រៀននៅក្នុងសាលាទេ។

ការពិតនៃការចេះភាសាមួយគឺថា ការរៀនភាសាមួយ ដែលមិនមែនជាមាតុភាសា អាចផ្តល់ឱកាសច្រើន មិនត្រឹមតែឱកាសសម្រាប់រៀនភាសាថ្មីទេ ប៉ុន្តែឱកាសសម្រាប់រៀនចំណេះដឹងថ្មីនៅក្នុងភាសាថ្មីនោះថែមទៀតផង។ ឱកាសរៀនភាសាថ្មីនេះ អាចបង្កការលំបាកកាន់តែធ្ងន់ធ្ងរទៅទៀត ទៅដល់ក្រុមមនុស្សប្រឈមនឹងបញ្ហាខ្វះឱកាសរៀនសូត្រ ដូចជាអនក្ខរជន ជនជាតិភាគតិច និងជនភៀសខ្លួន។ បញ្ហាយេនឌ័រ មានទំនាក់ទំនងជាមួយនឹងឱកាសទទួលការអប់រំ ជាពិសេសសម្រាប់ក្មេងស្រី និងស្ត្រី ដែលរស់នៅក្នុងស្ថានភាពក្រីក្រជួបការលំបាក។ នៅក្នុងសង្គម ដែលមានជីវភាពរស់នៅបែបបុរាណបំផុត គឺកុមារី និងស្ត្រី គឺជាមនុស្សដែលចេះតែមួយភាសា មានឱកាសក្នុងការរៀនភាសាពីសាលា និងពីការងារ ដែលមានប្រាក់កម្រៃ ឬត្រូវចេះតែភាសាជាតិ តិចជាងឱកាសរបស់កូនប្រុស បងប្អូនប្រុស និងប្តី។

ការសិក្សាជាច្រើនបានបង្ហាញថា ក្នុងករណីជាច្រើន ការបង្រៀន និងរៀន ដោយប្រើមាតុភាសា គឺមានសារប្រយោជន៍ច្រើន សម្រាប់លើកកំពស់សមត្ថភាពរៀនភាសា នៅក្នុងភាសាទីមួយ សម្រេចលទ្ធផលល្អក្នុងការរៀនមុខវិជ្ជាផ្សេង ហើយងាយស្រួលរៀនភាសាទីពីរ[3]ថែមទៀតផង។ ការប្រើប្រាស់ **មាតុភាសាជាគោលក្នុងការរៀន និងបង្រៀន** គួរចាត់ទុកជាច្បាប់។ បញ្ហាលំបាកមួយចំនួនដែលអ្នកប្រើមាតុភាសាជួបប្រទះ ក្នុងការរៀន និងបង្រៀនមានដូចខាងក្រោម :

- ជួនកាល មាតុភាសាមិនមែនជាភាសាសរសេរ។
- ជួនកាល មាតុភាសាមិនសូវទទួលស្គាល់ទូទៅថា ជាភាសាស្របច្បាប់។
- បច្ចេកវិទ្យាសមស្របសម្រាប់បំរើគោលបំណងអប់រំ ដោយប្រើមាតុភាសា មិនទាន់មាន ដូច្នេះត្រូវបង្កើតឡើងថ្មី។

- មិនសូវមានឯកសារគ្រប់គ្រាន់ សរសេរជាមាតុភាសា។
- ពហុភាសា អាចបង្កការលំបាកកាន់តែធ្ងន់ធ្ងរ ក្នុងការផ្តល់ការអប់រំ ដោយប្រើគ្រប់មាតុភាសារបស់អ្នករៀនទាំងអស់គ្នា។
- មិនទាន់មានគ្រូបង្រៀនគ្រប់គ្រាន់ ដែលមានសមត្ថភាពសមស្រប។
- អាចមានការជំទាស់របស់សិស្ស មាតាបិតា និងគ្រូបង្រៀន ក្នុងការរៀនមាតុភាសានៅសាលា។

## → សិទ្ធិប្រើភាសា

ភាសា មិនត្រឹមតែជាមធ្យោបាយមួយសម្រាប់ប្រាស្រ័យទាក់ទង និងសម្រាប់រៀនចំណេះដឹងថ្មីទេ ប៉ុន្តែភាសា ក៏ជាមូលដ្ឋានគ្រឹះនៃអត្តសញ្ញាណវប្បធម៌ និងអំណាច សម្រាប់មនុស្សម្នាក់ៗ និងសម្រាប់មនុស្សជាក្រុមផងដែរ។ ការគោរពភាសារបស់មនុស្សដទៃ ដែលមានមាតុភាសាខុសគ្នា គឺជាប្រភពនៃការរស់នៅរួមគ្នាប្រកបដោយសន្តិភាព។ ជីវភាពប្រកបដោយសន្តិភាព បែបនេះ មានប្រយោជន៍សម្រាប់ទាំងប្រជាជនភាគច្រើន និងសម្រាប់ប្រជាជនភាគតិច (ទោះបីជាជនជាតិដើមនៃប្រទេសមួយ ឬជាជនអន្តោប្រវេសន៍នៃប្រទេសមួយ) ហើយក៏មានប្រយោជន៍សម្រាប់ជនជាតិដើមភាគតិចផងដែរ។

ការទាមទារសិទ្ធិប្រើប្រាស់ភាសា ក៏ជាសិទ្ធិទីមួយក្នុងចំណោមសិទ្ធិ ទាំងឡាយដែលជនជាតិដើមភាគតិចត្រូវទាមទារប្រើអោយបាន ប្រសិនបើប្រឈមមុខនឹងស្ថានភាពកែប្រែ និងបដិវត្តន៍នយោបាយ។ ការទាមទារសិទ្ធិប្រើប្រាស់ភាសា រាប់ទាំងសិទ្ធិទាមទារអោយភាសាមានឋានៈស្របច្បាប់ និងមានឋានៈផ្លូវការសម្រាប់ភាសារបស់ប្រជាជនភាគតិច និងភាសារបស់ជនជាតិដើមភាគតិច រហូតដល់ការប្រើភាសាក្នុងការបង្រៀន និងប្រើនៅក្នុងសាលា និងស្ថាប័នផ្សេងៗ ក៏ដូចជាក្នុងប្រព័ន្ធសារព័ត៌មាន។ ទាក់ទងនឹងវិស័យអប់រំ **សិទ្ធិប្រើភាសា** បានចែងនៅក្នុងកិច្ចព្រមព្រៀងអន្តរជាតិ[4] សម្រាប់ប្រជាជនភាគតិច និងជនជាតិដើមភាគតិច ដូចមានកំណត់ខាងក្រោម :

- ការរៀនសូត្រនៅក្នុងសាលាត្រូវប្រើភាសារបស់ប្រជាជនភាគតិច ឬជនជាតិភាគតិច ប្រសិនបើត្រូវការ។
- ឱកាសរៀនភាសារបស់ប្រជាជនភាគច្រើន និងឱកាសរៀនភាសាប្រើប្រាស់ផ្លូវការនៅក្នុងប្រព័ន្ធអប់រំជាតិ។
- ការអប់រំ ដែលមានការផ្លាស់ប្តូរវប្បធម៌គ្នាទៅវិញទៅមក ដើម្បីលើកកំពស់ឥរិយាបថគោរពភាសា និង គោរពវប្បធម៌របស់ប្រជាជនភាគតិច និងភាសារបស់ជនជាតិភាគតិច។
- ឱកាសរៀនភាសាអន្តរជាតិ។

សិទ្ធិទទួលការអប់រំ ដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងអន្តរជាតិ សម្រាប់កម្មករ កម្មការិនីដែលជាជន អន្តោប្រវេសន៍ និងសមាជិកគ្រួសារ[5] ដោយធានាថា :

- ការបញ្ចូលកូនរបស់កម្មករ កម្មការិនីអោយចូលរៀននៅក្នុងសាលា ត្រូវគិតគូរអំពីការបង្រៀន ដោយប្រើភាសាប្រើប្រាស់នៅក្នុងប្រព័ន្ធសាលារៀន។
- ផ្តល់ឱកាសអោយកុមារទាំងនោះរៀនមាតុភាសា និងវប្បធម៌របស់ខ្លួន។

## → ការបង្រៀនភាសា

ភាសាសម្រាប់រៀន និងបង្រៀននៅក្នុងសាលា គឺជាមធ្យោបាយមួយសម្រាប់ប្រាស្រ័យទាក់ទង និងផ្លាស់ប្តូរចំណេះដឹង។ ភាសាក្នុងការរៀន និងបង្រៀន ខុសពី**ការបង្រៀនភាសា** ដែលទាមទារការបង្រៀន ទាំងវេយ្យាករណ៍ វាក្យស័ព្ទ និងទម្រង់សរសេរ និងនិយាយដែលមានកំណត់នៅក្នុងកម្មវិធីសិក្សាដោយផ្នែករបស់មុខវិជ្ជាភាសាទីពីរ ដែលខុសពីមាតុភាសា។ ការរៀនចេះភាសាមួយ នឹងទទួលបានឱកាសស្វែងយល់អំពីតម្លៃ និងផ្លូវជីវិតរបស់ពិភពលោក ហើយមានឱកាសស្វែងយល់ អំពីវប្បធម៌របស់សង្គមផ្សេង ហើយអាចជួយកាត់បន្ថយអារម្មណ៍ស្អប់ជនបរទេស។

ការចេះភាសាមួយផ្សេងទៀត ក៏មានសារៈសំខាន់សម្រាប់អ្នកនិយាយភាសារបស់ប្រជាជនភាគតិច និងប្រជាជនភាគច្រើន។ វិធីបង្រៀនភាសា គឺមានការប្រែប្រួលឥតឈប់ឈរ ហើយប្រហែលជាអាចខុសពីប្រទេសមួយទៅប្រទេសមួយ ឬខុសគ្នានៅក្នុងប្រទេសតែមួយក៏មាន។ ការខុសគ្នានេះ គឺអាស្រ័យលើភាពជឿនលឿន ឬភាពសាមញ្ញរបស់ភាសា និង អាស្រ័យលើបែបបទ និងវិធីសាស្ត្របង្រៀន ព្រមទាំងអាស្រ័យលើតួនាទីរបស់ភាសា ដែលត្រូវបង្រៀនផងដែរ។

## → ការអប់រំដោយប្រើពីរភាសា និងច្រើនភាសា

**ការអប់រំដោយប្រើពីរភាសា និងច្រើនភាសា** គឺនិយាយអំពីការប្រើប្រាស់ពីរ ឬច្រើនភាសាជាមធ្យោបាយសម្រាប់រៀន និងបង្រៀន។ នៅក្នុងឯកសារជាច្រើន ពាក្យអប់រំដោយប្រើពីរភាសាមានពីរប្រភេទ។ ប៉ុន្តែ អង្គការយូណេស្កូ អនុម័តប្រើពាក្យថា "ការអប់រំដោយប្រើច្រើនភាសា" នៅឆ្នាំ ១៩៩៩ នៅក្នុងសេចក្តីសម្រេចលេខ ១២ របស់សន្និសីទកំពូល។ ពាក្យនេះនិយាយអំពីការប្រើប្រាស់ ភាសាយ៉ាងតិចបី រួមទាំងមាតុភាសា ភាសាប្រើក្នុងតំបន់ ឬភាសាជាតិ និងភាសាអន្តរជាតិមួយ ដែលប្រើនៅក្នុងប្រព័ន្ធអប់រំ[6]។ សេចក្តីសម្រេចនេះ គាំទ្រទស្សនៈដែលថា តម្រូវការចូលរួមនៅក្នុង ប្រព័ន្ធជាតិ និងអន្តរជាតិ និងតម្រូវការជាក់ស្តែងរបស់សហគមន៍ដែលមានភាសា និងវប្បធម៌ ផ្សេងៗគ្នា អាចបំពេញបានតាមរយៈការអប់រំដោយប្រើច្រើនភាសា។ នៅក្នុងតំបន់ ដែលភាសារបស់ អ្នករៀន មិនប្រើជាផ្លូវការ ឬមិនមែនជាភាសាជាតិ ការអប់រំដោយ

ប្រើពីរភាសា ឬច្រើនភាសា អាចជួយជម្រុញអោយមានការប្រើប្រាស់មាតុភាសា នៅក្នុងការរៀន និងបង្រៀន ហើយក្នុងពេល តែមួយ អាចផ្តល់ឱកាសអោយអ្នករៀនចេះភាសាផ្សេង ដែលប្រើប្រាស់ទូទៅជាងនៅក្នុងប្រទេស និងនៅទូទាំងសកលលោក។ វិធីសាស្ត្រអប់រំដោយបន្ថែមច្រើនភាសា គឺខុសពីវិធីសាស្ត្រអប់រំ ដោយបន្ថយចំនួនភាសា ដែលមានគោលបំណងចង់អោយកុមាររៀនតែភាសាទីពីរ ដែលជាភាសាសម្រាប់រៀន និងបង្រៀនតែប៉ុណ្ណោះ។

# ក្របខ័ណ្ឌ
# សម្រាប់ការ
# និងការអប់រំ

# កម្មភាពរួម ប្រើភាសា

ស្ថានភាព និងតួនាទីរបស់ភាសា នៅកម្រិតអន្តរជាតិ គឺជាប្រធានបទមួយនៅក្នុងសេចក្តីថ្លែងការណ៍ អនុសាសន៍ និងនៅក្នុងកិច្ចព្រមព្រៀងជាច្រើន។ មានសេចក្តីថ្លែងការណ៍ អនុសាសន៍ និងកិច្ចព្រមព្រៀងមួយចំនួន និយាយជាពិសេស អំពីភាសា និងការអប់រំ។ ផ្នែកនេះ ចាប់ផ្តើមពិភាក្សាអំពីភាសា នៅក្នុងក្របខ័ណ្ឌសកម្មភាពរបស់កិច្ចព្រមព្រៀងអង្គការសហប្រជាជាតិ និងច្បាប់នានា ហើយបន្ទាប់មក ផ្នែកនេះ លើកយកឯកសារជំនួយស្មារតីមកពិភាក្សាបន្ថែមទៀត ដែលទាក់ទងនឹងអាណត្តិ និងបេសកកម្មរបស់អង្គការយូណេស្កូ នៅលើឆាកអន្តរជាតិ។ សេចក្តីថ្លែងការណ៍ និងអនុសាសន៍ ទទួលបានពីសន្និសីទអន្តររដ្ឋាភិបាលនានាក៏ត្រូវបានលើកយកមកពិចារណា និងពិភាក្សានៅក្នុងផ្នែកនេះផងដែរ[7]។

សម្រាប់គោលបំណងរបស់ឯកសារនេះ គឺស្របតាមគោលបំណងដែលបានកំណត់នៅក្នុងកិច្ចព្រមព្រៀងអន្តរជាតិនានា។ គោលបំណងនៃការបង្ហាញ និងពន្យល់អំពីក្របខ័ណ្ឌសកម្មភាព តាមលក្ខណៈបែបនេះ គឺសំដៅបង្ហាញរូបភាពពិត របស់កិច្ចព្រមព្រៀងអន្តរជាតិស្តីពីភាសា និងសារៈសំខាន់របស់ភាសានៅក្នុងប្រព័ន្ធអប់រំ មុននឹងឈានចូលទៅពិភាក្សាអំពីសេចក្តីណែនាំរបស់ អង្គការយូណេស្កូ ស្តីពីភាសា និងការអប់រំនៅក្នុងជំពូក៣។

# ក.ច្បាប់កំណត់តាមស្តង់ដាអង្គការសហប្រជាជាតិ

*ច្បាប់មួយក្នុងចំណោមច្បាប់មូលដ្ឋាន ដែលបានកំណត់តាមស្តង់ដាអង្គការសហប្រជាជាតិ* **គឺសេចក្តីថ្លែងការសកលស្តីពីសិទ្ធិមនុស្ស** *ដែលបានប្រកាស និងអនុម័តកាលពីឆ្នាំ ១៩៤៨ បានដាក់ចេញនូវគោលការណ៍មូលដ្ឋានប្រឆាំងនឹងការរើសអើងក្នុងការប្រើភាសាដែលបានចែងថា"មាត្រា២ : ពលរដ្ឋគ្រប់ៗរូប មានសិទ្ធិ និងសេរីភាពទាំងអស់ ដូចមានចែងនៅក្នុងសេចក្តីប្រកាសនេះ ដោយមិនប្រកាន់អ្វីទាំងអស់ ដូចជា ......... ភាសាជាដើម"។*

*សិទ្ធិរបស់ពលរដ្ឋ នៃជនជាតិភាគតិច ត្រូវបានចែង បន្ទាប់មកទៀត នៅក្នុងកតិកាសញ្ញា* **អន្តរជាតិឆ្នាំ ១៩៦៦ ស្តីពីសិទ្ធិស៊ីវិល និងសិទ្ធិនយោបាយ** *និងនៅក្នុង***សេចក្តីប្រកាសឆ្នាំ ១៩៩២ ស្តីពីសិទ្ធិពលរដ្ឋជនជាតិភាគតិច ជនជាតិដើមភាគតិច ឬសិទ្ធិសាសនា។** *ចំណែកមាត្រា២៧ របស់កតិកាសញ្ញាអន្តរជាតិនេះ និយាយទូទៅអំពីសិទ្ធិពលរដ្ឋជនជាតិភាគតិច "ក្នុងការប្រើប្រាស់មាតុភាសារបស់ខ្លួន ............ នៅក្នុងសហគមន៍ជាមួយក្រុមជនជាតិ ដូចគ្នា"។ សេចក្តីប្រកាសនេះ*

និយាយពាក់ព័ន្ធយ៉ាងច្បាស់ ជាមួយបញ្ហាភាសានៅក្នុងវិស័យអប់រំ ដូចមានចែងនៅក្នុងមាត្រា៤ ដែលចែងថា ពលរដ្ឋជនជាតិភាគតិច គួរមានឱកាសគ្រប់គ្រាន់ "ដើម្បីរៀនមាតុភាសា ឬទទួលបានការរៀន និងបង្រៀនជាមាតុភាសា" ហើយចែងទៀតថា គួរចាត់វិធានការ "ដើម្បីបំផុស និងផ្សព្វផ្សាយអំពីចំណេះដឹងផ្នែកភាសា និងវប្បធម៌របស់ជនជាតិដើមភាគតិច"។

សិទ្ធិទទួលការអប់រំរបស់ជនជាតិភាគតិច ត្រូវបានចែងនៅក្នុង**អនុសញ្ញាលេខ ១៦៩ របស់អង្គការ ILO ឆ្នាំ ១៩៨៩ ស្តីពីជនជាតិភាគតិច និងជនជាតិដើមរស់នៅក្នុងប្រទេសឯករាជ្យ**។ មាត្រា២៨ តម្រូវថា "កុមារកូនជនជាតិដើមភាគតិច បើអាចធ្វើបាន ត្រូវរៀនអាន និងសរសេរមាតុភាសាជនជាតិដើមរបស់ខ្លួន ឬរៀនអាន និងសរសេរភាសានិយមប្រើបំផុតនៅក្នុងក្រុមជនជាតិដើមភាគតិច" ហើយមាត្រានេះ ទាមទារទៀតថា "គួរចាត់វិធានការអោយបានគ្រប់គ្រាន់ ដើម្បីធានាថា ជនជាតិដើមភាគតិច ត្រូវមានឱកាសរៀនមាតុភាសាអោយបានស្ទាត់ជំនាញ ឬរៀនភាសាផ្លូវការមួយ នៅក្នុងប្រទេសដែលជនជាតិដើមភាគតិចរស់នៅ"។ មាត្រានេះ បញ្ជាក់ទៀតថា "គួរចាត់វិធានការ ដើម្បីការពារ និងលើកកំពស់ការអភិវឌ្ឍ និងការអនុវត្ត ប្រើភាសាជនជាតិដើមភាគតិច"។

ទាក់ទងនឹងជនជាតិ មិនមែនជនជាតិកំណើតរស់នៅក្នុងប្រទេសមួយ **សេចក្តីថ្លែងការណ៍ឆ្នាំ ១៩៨៥ ស្តីពីសិទ្ធិពលរដ្ឋ ដែលមិនមែនជាប្រជាពលរដ្ឋរបស់ប្រទេសដែលពលរដ្ឋនោះរស់នៅ** មានចែងនៅក្នុងមាត្រា៥ នៃសេចក្តីប្រកាសនេះ ដែលចែងថា "ជនបរទេស ត្រូវមានសិទ្ធិប្រើ និងថែរក្សាមាតុភាសា វប្បធម៌ និងប្រពៃណីរបស់ខ្លួន"។ **អនុសញ្ញាអន្តរជាតិឆ្នាំ ១៩៩០ ស្តីពីការការពារសិទ្ធិរបស់ពលករជាជនអន្តោប្រវេសន៍ និងសមាជិកគ្រួសាររបស់ពលករជាជនអន្តោប្រវេសន៍** បានចែងថា "រដ្ឋដែលផ្តល់ការងារអោយពលករជាជនអន្តោប្រវេសន៍ គួរអនុវត្តគោលនយោបាយមួយ ...... ដែលមានបំណងជួយសម្រួលដល់ការបញ្ចូលកូនពលករជាជនអន្តោប្រវេសន៍ អោយចូលរៀននៅក្នុងសាលារៀន ដោយបង្រៀនភាសាអ្នកស្រុកដែលគេរស់នៅដល់កុមារទាំងនោះផងដែរ" ហើយបង្រៀនមាតុភាសា និងវប្បធម៌របស់កុមារកូនពលករអន្តោប្រវេសន៍ផងដែរ"។ រដ្ឋទាំងនោះ ក៏អាចផ្តល់កម្មវិធីអប់រំពិសេស ដោយប្រើ មាតុភាសារបស់កូនពលករអន្តោប្រវេសន៍ផងដែរ" (មាត្រា៤៥)។

**អនុសញ្ញាឆ្នាំ១៩៨៩ ស្តីពីសិទ្ធិកុមារ** ផ្តល់ពន្លឺដល់កត្តាសំខាន់មួយទៀត ទាក់ទងនឹងបញ្ហាភាសានៅក្នុងការអប់រំ។ អនុសញ្ញានេះ លើកឡើងដោយសង្កត់ធ្ងន់ថា ភាសាត្រូវតែមានតម្លៃមួយនៅក្នុងការអប់រំ។ មាត្រា២៩ បានចែងថា "ការអប់រំកុមារត្រូវតែមានគោលបំណងឈានឆ្ពោះទៅរក ........ ការអភិវឌ្ឍការគោរពអត្តសញ្ញាណ ភាសា និងតម្លៃ វប្បធម៌ដែលកុមារគោរពកុមារផងដែរ"។

# ខ. សេចក្ដីថ្លែងការណ៏ និង អនុសញ្ញារបស់អង្គការយូណេស្កូ

*អាណត្តិ និងបេសកកម្មរបស់អង្គការយូណេស្កូ បានកំណត់ទិសដៅឈានទៅដោះស្រាយបញ្ហាភាសា។* ក្នុងន័យនេះ មាត្រា១ នៃធម្មនុញ្ញរបស់អង្គការយូណេស្កូ បានចែងអំពីគោលការណ៍មូលដ្ឋានមួយដែលថា *ភាសាមិនគួរចាត់ទុកជាដើមហេតុនៃការរើសអើងឡើយ។* មាត្រានេះចែងថា *"សិទ្ធិមនុស្ស និងសេរីភាពគ្រឹះ ......... គឺជាកម្មសិទ្ធិរបស់ប្រជាពលរដ្ឋទូទាំងពិភពលោក ដោយមិនប្រកាន់ជាតិសាសន៍ ភេទ ភាសា ឬ សាសនាឡើយ"។*

*កាន់តែទាក់ទងជាមួយនឹងការអប់រំថែមទៀត* **អនុសញ្ញាឆ្នាំ ១៩៦០ ប្រឆាំងនឹងការរើសអើងនៅក្នុងការអប់រំ** *បានចែងច្បាស់អំពីសិទ្ធិទទួលការអប់រំរបស់ពលរដ្ឋជាជនជាតិដើមភាគតិច។* មាត្រា៥ និយាយពាក់ព័ន្ធយ៉ាងពិសេសជាមួយនឹងបញ្ហាភាសា ព្រោះតួនាទីរបស់មាតុភាសា និងភាសារបស់ ជនជាតិភាគតិច មាននិយមន័យច្បាស់ថា *"ពលរដ្ឋជនជាតិភាគតិច (មានសិទ្ធិ) អនុវត្តសកម្មភាព អប់រំសម្រាប់ជនជាតិ គិតទាំង ............ ការប្រើភាសា និងបង្រៀនភាសាជនជាតិ អោយតែជនជាតិនោះ ត្រូវបានបិទសិទ្ធិ មិនអោយសមាជិករបស់ខ្លួនយល់អំពីវប្បធម៌ និងភាសារបស់ខ្លួនជាទូទៅ ហើយអោយតែជនជាតិនេះ មិនមានសិទ្ធិចូលរួមនៅក្នុងសកម្មភាពអប់រំរបស់ខ្លួន"។*

**អនុសាសន៍ឆ្នាំ ១៩៧៦ ស្ដីពីការអភិវឌ្ឍការអប់រំមនុស្សពេញវ័យ** *បានផ្ដល់សារៈសំខាន់ដល់តួនាទីរបស់មាតុភាសា ព្រោះអនុសញ្ញានេះ ផ្ដល់អនុសាសន៍អោយប្រើប្រាស់មាតុភាសា សម្រាប់ការរៀន និងបង្រៀន ហើយអនុសាសន៍នេះ ក៏អនុម័តគោលការណ៍ទូទៅមួយ ស្ដីពីការរៀនភាសាផងដែរ។* មាត្រា២២ ចែងថា *"ដោយមិនប្រកាន់ជនជាតិភាគតិច សកម្មភាពអប់រំមនុស្សពេញវ័យគួរជួយអោយមនុស្សពេញវ័យមានសមត្ថភាព ... អប់រំចំណេះដឹងសម្រាប់ខ្លួនឯង និងសម្រាប់អប់រំកូន ដោយប្រើមាតុភាសា មានសមត្ថភាពអភិវឌ្ឍវប្បធម៌ និងរៀនភាសាផ្សេង និងមាតុភាសាផងដែរ"។*

*តួនាទីរបស់មាតុភាសានៅក្នុងការអប់រំ ក៏មានចែងនៅក្នុង***សេចក្ដីថ្លែងការណ៍ឆ្នាំ ១៩៧៨ ស្ដីពីជាតិសាសន៍ និងការប្រកាន់ពូជសាសន៍** *ដែលមាត្រា៩ បានផ្ដល់អនុសាសន៍ថា "គួរចាត់វិធានការ ដើម្បីធានាថា កុមារ (កូនប្រជាពលរដ្ឋជាជនបរទេស) ទទួលបានការរៀនសូត្រអំពីមាតុភាសារបស់ខ្លួន"។*

**សេចក្តីថ្លែងការណ៍ឆ្នាំ ១៩៩៥ និងក្របខណ្ឌ័សកម្មភាពរួមស្តីពីការអប់រំ ដើម្បីសន្តិភាព សិទ្ធិមនុស្ស និងប្រជាធិបតេយ្យ** *ចលនាអោយមានការរៀនភាសាបរទេស (មាត្រា១៩) និង "គោរពសិទ្ធិទទួលការអប់រំរបស់ពលរដ្ឋ ជាជនជាតិភាគតិច ព្រមទាំងគោរពសិទ្ធិអប់រំរបស់ជនជាតិដើមភាគតិចផងដែរ" ដើម្បីធានាលើកកំពស់ការចែករំលែកចំណេះដឹងរវាង សហគមន៍ និង សហគមន៍ ព្រមទាំងរវាងប្រទេស និងប្រទេសផងដែរ (មាត្រា២៩)។*

**សេចក្តីថ្លែងការសកលស្តីពីនានាភាពនៃវប្បធម៌អនុម័តឆ្នាំ ២០០១** *បានចែងអំពីសារៈសំខាន់របស់ភាសា សម្រាប់លើកកំពស់នានាភាពនៃវប្បធម៌។ មាត្រា៦ របស់ផែនការសកម្មភាពសម្រាប់អនុវត្តសេចក្តីថ្លែងការណ៍សកលនេះ បានអោយនិយមន័យនៃតួនាទីរបស់ភាសា នៅក្នុងវិស័យអប់រំ ដោយគិតទាំងការគោរពមាតុភាសា នានាភាពនៃភាសា នៅគ្រប់កម្រិតអប់រំទាំងអស់ ហើយលើកកំពស់ការប្រើប្រាស់ច្រើនភាសា តាំងពីវ័យកុមារតូច។*

# គ. លទ្ធផលទទួលបានពីសន្និសីទអន្តរជាតិនានា

*សន្និសីទកំពូលពិភពលោកជាច្រើន ដែលទើបរៀបចំក្នុងពេលប៉ុន្មានឆ្នាំថ្មីៗនេះ ក្រោមការជួយឧបត្ថម្ភរបស់អង្គការ សហប្រជាជាតិ និងការរៀបចំវេទិកានានាតាមកលក្ខណៈអន្តររដ្ឋាភិបាល បានកត់សម្គាល់ និងអោយតម្លៃទៅលើសារៈសំខាន់របស់ភាសា។ ឧទាហរណ៍មួយ គឺ* **សេចក្តីថ្លែងការណ៍ ក្រុងប៉េកាំង និងក្របខ័ណ្ឌសកម្មភាព** *ដែលបានអនុម័ត ក្នុងឆ្នាំ ១៩៩៥ នៅសន្និសីទពិភពលោក លើកទីបួន ស្តីពីស្ត្រី បានអនុម័តគោលការណ៍មួយ ធានាអោយមានឱកាសស្មើភាពគ្នា ក្នុងការទទួលការអប់រំ ដែលត្រូវធានាសម្រេចអោយបាន តាមរយៈការលុបបំបាត់ "ការរើសអើងក្នុងការអប់រំ នៅគ្រប់កម្រិតទាំងអស់ ដោយយកភាសាជាមូលដ្ឋាន"។*

*ការរៀន និងបង្រៀនដោយប្រើមាតុភាសា កំពុងក្លាយជាបញ្ហាថ្មីមួយ។* **សេចក្តីថ្លែងការណ៍ក្រុងដេលី និងក្របខ័ណ្ឌសកម្មភាព** *អនុម័តក្នុងឆ្នាំ ១៩៩៣ នៅសន្និសីទកំពូលស្តីពីការអប់រំសម្រាប់ទាំងអស់គ្នា បានយកចិត្តទុកដាក់លើបញ្ហា នៃការប្រើមាតុភាសាសម្រាប់ការរៀន និងបង្រៀន ដោយគាំទ្រដល់ "ការរៀន និងបង្រៀនដោយប្រើមាតុភាសា ទោះបីជាក្នុងករណីខ្លះ ចាំបាច់ត្រូវអោយអ្នករៀន ស្ទាត់ជំនាញភាសាជាតិ ឬភាសាផ្សេងទៀត ដែលនិយមប្រើ ប្រសិនបើ សិស្សត្រូវប្រើប្រាស់ភាសាទាំងនោះនៅក្នុងសង្គម"។ តម្រូវការចំណេះដឹង "តួនាទីដ៏សំខាន់របស់មាតុភាសា*

សម្រាប់ ការរៀន និងបង្រៀន" ក៏ត្រូវបានកំណត់ច្បាស់នៅក្នុងសេចក្តីថ្លែងការណ៍ក្រុង Amman ឆ្នាំ ១៩៩៦ ដែលជាសេចក្តីថ្លែងការណ៍របស់កិច្ចប្រជុំពាក់កណ្តាលសហស្សវត្សរ៍របស់វេទិកាពិគ្រោះយោបល់អន្តរជាតិ ស្តីពីការអប់រំសម្រាប់ ទាំងអស់គ្នា។

**សេចក្តីថ្លែងការណ៍ក្រុងហាំប៊ឹក ស្តីពីការរៀនសូត្ររបស់មនុស្សពេញវ័យ** អនុម័តនៅសន្និសីទអន្តរជាតិលើកទី៥ ស្តីពីការ អប់រំសម្រាប់មនុស្សពេញវ័យ បានចែងអំពីសារៈសំខាន់នៃបញ្ហាសម្រាប់ក្រុមជនជាតិភាគតិច និងក្រុមជនជាតិដើមភាគតិច ហើយដាក់ចេញនូវអនុសាសន៍ថា "សិទ្ធិរៀនមាតុភាសា ត្រូវតែគោរព និងអនុវត្តអោយបាន (មាត្រា១៥)។ **សេចក្តីថ្លែងការណ៍ក្រុមវីណា និងកម្មវិធីសកម្មភាព** អនុម័តនៅសន្និសីទពិភពលោកស្តីពីសិទ្ធិមនុស្សឆ្នាំ (១៩៩៣) និយាយទូទៅច្រើននៅក្នុងផ្នែកទីមួយ កថាខ័ណ្ឌ ១៩ ដែលចែងថា "ពលរដ្ឋជាប្រជាជនភាគតិច មានសិទ្ធិ ...... ប្រើប្រាស់ មាតុភាសាទាំងនៅក្នុងបរិយាកាសឯកជន និងសាធារណៈ ដោយសេរី និងគ្មានការរំខាន ឬដោយ គ្មានការរើសអើង"។

**សេចក្តីថ្លែងការណ៍ពិភពលោកឆ្នាំ ១៩៩៨ ស្តីពីការអប់រំឧត្តមសិក្សាសម្រាប់សតវត្សរ៍ទី២១ : ទស្សនៈវិស័យ និងសកម្មភាព** បានចែងអំពីសារៈសំខាន់នៃពហុភាសានៅក្នុងថ្នាក់ឧត្តមសិក្សា។ ដើម្បីបំផុស និងលើកកំពស់ការយល់ដឹង ជាអន្តរជាតិអំពី "ការអនុវត្តការប្រើប្រាស់ពហុភាសា និងអនុវត្តកម្មវិធីផ្លាស់ប្តូរបទពិសោធ និងចំណេះដឹងរវាងសិស្ស និងសិស្ស ព្រមទាំងរវាងសាលា និងសាលា គួរជាផ្នែកដ៏មានសារៈសំខាន់របស់ប្រព័ន្ធអប់រំឧត្តមសិក្សា" (មាត្រា១៥)។

នៅក្នុង វិស័យភាសា និងការអប់រំ របាយការណ៍ និងអនុសាសន៍ថ្មីៗ ទទួលបានពីសន្និសីទអន្តរជាតិស្តីពីអប់រំ (ICE) បានផ្តល់សារៈសំខាន់ទៅលើ :

- ការរៀន និងបង្រៀន ដោយប្រើមាតុភាសា នៅពេលចាប់ផ្តើមចូលរៀនក្នុងសាលា ចំណេះទូទៅសម្រាប់ការរៀនចិត្តគុរុកោសល្យ សម្រាប់រៀនអំពីសង្គមវិទ្យា និងវប្បធម៌។[8]
- ការអប់រំដោយប្រើច្រើនភាសា ដែលមានទស្សនវិស័យការពារអត្តសញ្ញាណវប្បធម៌ និងលើកកំពស់ចលនាបំលាស់លំនៅ និងការពិភាក្សា។[9]
- ការរៀនភាសាបរទេស ក៏ជាចំណែកមួយនៃការអប់រំរៀនអំពីអន្តរវប្បធម៌ ដែលមានបំណងលើកកំពស់ការយល់ដឹង រវាងសហគមន៍ និងសហគមន៍ និងរវាងប្រទេស និង ប្រទេស។[10]

# សេចក្តីណែ

# របស់អង្គការ

# ស្តីពីកាសា

# ឆ្នាំ យូណេស្កូ និងការអប់រំ

មានសេចក្តីណែនាំមូលដ្ឋាន ដែលអាចប្រើទូទៅនៅគ្រប់ឯកសារទាំងអស់នៅគ្រប់កិច្ចព្រមព្រៀង និងអនុសាសន៍ទាំងអស់ ដែលបានដាក់ចេញក្នុងរយៈពេលជាច្រើនឆ្នាំកន្លងមក តាមអាណត្តិ និងបេសកកម្មរបស់អង្គការយូណេស្កូ ដើម្បីអនុវត្តសកម្មភាពនៅក្នុងវិស័យភាសា និងអប់រំនេះ។ ដោយសារមានគោលការណ៍ទាំងនេះ ទើបយើងមានលទ្ធភាពបង្កើត និងកំណត់វិធីសាស្ត្រថ្មីៗរបស់អង្គការយូណេស្កូ សម្រាប់ភាសា និងការអប់រំ ក្នុងសតវត្សរ៍ទី២១ ហើយវិធីសាស្ត្រនេះ មានតួនាទីកំណត់ជំហររបស់សហគមន៍អន្តរជាតិ នៅក្នុងរដ្ឋជាសមាជិកទាំងអស់។ សេចក្តីណែនាំនេះ ត្រូវបានបង្កើតឡើងឈរលើមូលដ្ឋាននៃការពិនិត្យ និងវិភាគសេចក្តីថ្លែងការណ៍ និងអនុសាសន៍ចាស់ៗ និងដាក់ចេញនូវគោលគំនិត សំខាន់ៗអំពីបញ្ហាដ៏ស្មុគ្រស្មាញ និងពិបាកដោះស្រាយនៅក្នុងវិស័យភាសា និងការអប់រំ។

គោលការណ៍ នេះត្រូវបានចែកចេញជាបីផ្នែក ៖

១. អង្គការយូណេស្កូ គាំទ្រការប្រើប្រាស់មាតុភាសា សម្រាប់ការរៀន និងបង្រៀនជាមធ្យោបាយលើកកំពស់ គុណភាពអប់រំ ដោយពង្រីងសមត្ថភាព និងបទពិសោធរបស់អ្នករៀន និងគ្រូបង្រៀន។

២. អង្គការយូណេស្កូ គាំទ្រការអប់រំ ដោយប្រើពីរភាសា និងច្រើនភាសានៅគ្រប់កម្រិតទាំងអស់ក្នុងប្រព័ន្ធអប់រំ ជាមធ្យោបាយក្នុងការលើកកំពស់សមភាពសង្គម និងយេនឌ័រ ហើយប្រើជាសមាសភាពគន្លឹះមួយរបស់សង្គមដែលប្រើច្រើនភាសា។

៣. អង្គការយូណេស្កូ គាំទ្រភាសា ថាជាសមាសភាពមួយដ៏សំខាន់របស់ការអប់រំ ដែលមានវប្បធម៌ចំរុះ ដើម្បីបំផុស និងលើកកំពស់ការយល់ដឹងអំពីភាសា រវាងក្រុមប្រជាជនដែលប្រើភាសាផ្សេងគ្នា និងធានាលើកកំពស់ការគោរពសិទ្ធិមូលដ្ឋានរបស់ពលរដ្ឋក្នុងការប្រើភាសា។

*ខាងក្រោមជាការពន្យល់កាន់តែច្បាស់អំពីគោលការណ៍មូលដ្ឋាននីមួយៗ។*

# គោលការណ៍ I

អង្គការយូណេស្កូ គាំទ្រការប្រើប្រាស់មាតុភាសា សម្រាប់ការរៀន និងបង្រៀន[11] ជាមធ្យោបាយលើកកំពស់គុណភាពអប់រំ ដោយពង្រឹងសមត្ថភាព និងបទពិសោធរបស់អ្នករៀន និងគ្រូបង្រៀន។

(I) ការរៀន និងបង្រៀន ដោយប្រើមាតុភាសា គឺជាកត្តាសំខាន់សម្រាប់ការរៀន និងបង្រៀន[12] និងសម្រាប់ការរៀនអក្ខរកម្ម[13]ផងដែរ ហើយការរៀន និងបង្រៀនដោយប្រើមាតុភាសាគួរ "ពង្រីក និងបង្កើនការប្រើប្រាស់នៅកម្រិត អប់រំខ្ពស់ៗអោយកាន់តែច្រើន ប្រសិនបើអាចធ្វើបាន" :[14]

- *"សិស្សគ្រប់ៗរូប គួរចាប់ផ្តើមការអប់រំចំណេះទូទៅ រៀនជាមាតុភាសា"[15]។*
- *"អនក្ខរជនមនុស្សចាស់ គួរចាប់ផ្តើមរៀនអក្ខរកម្មជំហានដំបូង ដោយប្រើមាតុភាសា ហើយបន្ទាប់មក រៀនភាសាទីពីរបន្ត ប្រសិនបើអ្នករៀនមានបំណងចង់រៀន ហើយមានសមត្ថភាពរៀន"[16]។*
- *ប្រសិនបើ តំបន់ណាមួយ ប្រើភាសាច្រើន "គួររៀបចំ និងរកមធ្យោបាយ បង្រៀនសិស្សទៅតាមក្រុម និយាយមាតុភាសាដូចគ្នា"[17]។*
- *"ប្រសិនបើ មិនអាចជៀសរួច ត្រូវបញ្ចូលសិស្សចេះមាតុភាសាចំរុះ ការរៀន និងបង្រៀន គួរប្រើភាសាមួយដែលមិនសូវបង្កការលំបាកខ្លាំងដល់អ្នករៀន ហើយជាពិសេសជួយសិស្សទាំងឡាយណា ដែលមិនចេះនិយាយភាសា ប្រើក្នុងការរៀន និងបង្រៀនអោយបានច្រើន"[18]។*

(II) "អក្ខរកម្ម ក៏អាចបង្រៀនបានដែរ ប្រសិនបើមានឯកសារអានច្រើនគ្រប់គ្រាន់ សម្រាប់ទាំងយុវវ័យ និងមនុស្សចាស់ និងសម្រាប់កុមាររៀននៅសាលា ហើយមានឯកសារគ្រប់គ្រាន់សម្រាប់ទាំងការលេងកំសាន្ត និងសម្រាប់ រៀនសូត្រផងដែរ":[19]

- *ការផលិត និងចែកផ្សព្វផ្សាយឯកសាររៀន និងបង្រៀន និងឯកសារអានផ្សេងៗជាមាតុភាសារបស់អ្នក ប្រើប្រាស់ គួរពង្រីង និងបង្កើនឡើងអោយបានច្រើន។[20]*

(III) *ទាក់ទងនឹងការបណ្តុះបណ្តាលគ្រូ និងការរៀន និងបង្រៀន ជាមាតុភាសា : "គ្រប់ផែនការអប់រំទាំងអស់ គួរបញ្ចូលគ្រប់ដំណាក់កាល នៃការបណ្តុះបណ្តាលគ្រូ និងការបំប៉នគ្រូ អោយមានចំនួនគ្រូដែលមានសមត្ថភាពពេញលេញ អោយបានច្រើនគ្រប់គ្រាន់ នៅទូទាំងប្រទេសអោយចូលរៀន។ គ្រូទាំងនោះ ត្រូវស្គាល់អំពីជីវភាព និងចេះភាសា ប្រហាក់ប្រហែលនឹងអ្នករៀន ហើយមានសមត្ថភាពគ្រប់គ្រាន់ក្នុងការបង្រៀនសិស្ស ដោយប្រើមាតុភាសា"។[21]*

# គោលការណ៍ II

អង្គការយូណេស្កូ គាំទ្រការអប់រំ ដោយប្រើពីរភាសា និងច្រើនភាសានៅគ្រប់កម្រិតទាំងអស់ក្នុងប្រព័ន្ធអប់រំ[22] ជាមធ្យោបាយក្នុងការលើកកំពស់សមភាពសង្គម និងយេនឌ័រ ហើយជាសមាសភាពគន្លឹះមួយរបស់សង្គមដែលប្រើច្រើនភាសា។

(I) "ការប្រាស្រ័យទំនាក់ទំនង ការបញ្ចេញមតិយោបល់ និងសមត្ថភាពស្តាប់ និងពិភាក្សា (គួរលើកកំពស់ និងពង្រឹងអោយបានខ្លាំងក្លា) ជាដំបូង ជាមាតុភាសា បន្ទាប់មក (ប្រសិនបើមាតុភាសាខុសពីភាសាផ្លូវការ ឬភាសាជាតិ) ទើបបំផុសការប្រើភាសាផ្លូវការ (ឬភាសាជាតិ) ប្រើទូទៅនៅក្នុងប្រទេស អាចប្រើភាសាមួយ ឬច្រើនភាសា[23]" តាមរយៈកត្តាសំខាន់ៗ :

- *"ការរៀន និងចេះប្រើភាសាទីពីរ តាំងពីវ័យក្មេង បន្ថែមទៅលើមាតុភាសា[24]"។*
- *ការបញ្ចូល"ភាសាទីពីរ ជាមុខវិជ្ជាមួយសម្រាប់ការរៀន និងបង្រៀន[25] គួរបង្កើនជាបណ្តើរៗ[26] ហើយមិនគួរបង្កើនរហូតដល់យកភាសាទីពីរមកប្រើសម្រាប់ការរៀន និងបង្រៀនច្រើនពេកទេ។ ការប្រើភាសាទីពីរ សម្រាប់ការរៀន និងបង្រៀន គួរប្រើច្រើនល្មម "នៅពេលសិស្សចេះច្រើននិងយល់ច្រើនអំពីភាសាទីពីរនោះ"[27]។*
- *"ការអប់រំបន្ត ដោយប្រើភាសាទីពីរ នៅថ្នាក់បឋមសិក្សា ដោយឈរលើមូលដ្ឋាននៃការប្រើប្រាស់ ជាមធ្យម នៅក្នុងការរៀន និងបង្រៀន ដូច្នេះ ការប្រើពីរភាសា ដើម្បីគ្រប ដណ្តប់ចំណេះដឹងពីការអប់រំ នៅតាមសាលា រហូតដល់ ថ្នាក់សាកលវិទ្យាល័យ"។*
- *សកម្មភាពរៀន ដោយលក្ខណៈពេញលេញ និងរៀនច្រើនមុខវិជ្ជា ដោយប្រើភាសាយ៉ាងហោចណាស់ ភាសា ទីបី នៅថ្នាក់មធ្យមសិក្សា នៅពេលសិស្សចេញពីសាលា សិស្សនឹងមានចំណេះផ្នែកការងារ ដោយចេះប្រើបីភាសា ដែលចំណេះដឹងបីភាសានេះ គឺជាជំនាញភាសាធម្មតា ដែលត្រូវការប្រើនៅក្នុងសតវត្សរ៍ទី២១នេះ។[28]*

(II) ការផ្លាស់ប្តូរចំណេះដឹង និងបទពិសោធជាអន្តរជាតិរបស់គ្រូបង្រៀននៅបឋមសិក្សា និងមធ្យមសិក្សា (គួរបំផុស និងលើកកំពស់អោយបានល្អប្រសើរ) សម្រាប់ការបង្រៀនមុខវិជ្ជា នៅក្នុងសាលា នៅតាមប្រទេសផ្សេង ដោយ ប្រើមាតុភាសារបស់គ្រូ ជាលទ្ធផលសិស្ស នឹងទទួលបានទាំងចំណេះដឹងលើមុខវិជ្ជារៀន និងជំនាញភាសាផងដែរ ។[29]

(III) ការប្រឹងប្រែង និងយកចិត្តទុក គួរផ្តោតទៅលើការបង្កើត និងតាក់តែង"គោលនយោបាយជាតិអោយល្អ ក្នុងគោលបំណងលើកកំពស់ការបង្រៀនភាសា នៅតាមប្រព័ន្ធកុំព្យូទ័រ និងអ៊ីធឺណេត (ហើយពង្រឹង និងពង្រីកអោយកាន់តែច្រើន) ដោយមានជំនួយគាំទ្រពីអន្តរជាតិ សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីជួយសម្រួលដល់ការរៀបរៀងឯកសារ និងបង្កើតឯកសារដែលងាយយល់ និងងាយប្រើ ស្តីពីការរៀនភាសាតាមប្រព័ន្ធអេលិចត្រូនិច ហើយក៏លើកកំពស់ជំនាញ និងសមត្ថភាពធនធានមនុស្សនៅក្នុងវិស័យនេះអោយច្រើនផងដែរ ។[30]

# គោលការណ៍ III

អង្គការយូណេស្កូ គាំទ្រភាសា ថាជាសមាសភាពមួយដ៏សំខាន់ របស់ប្រព័ន្ធអប់រំ ដែលមានវប្បធម៌ចំរុះ ដើម្បីបំផុស និងលើកកំពស់ការយល់ដឹងអំពីភាសា រវាងក្រុមប្រជាជន ដែលប្រើភាសាផ្សេងគ្នា និងធានាលើកកំពស់ការគោរពសិទ្ធិមូលដ្ឋានរបស់ពលរដ្ឋក្នុងការប្រើភាសា។

(I) ចាត់វិធានការ ដើម្បី "លុបបំបាត់ការរើសអើងនៅក្នុងការអប់រំ នៅគ្រប់កម្រិតទាំងអស់ ដោយមិនប្រកាន់ ភេទ ជាតិសាសន៍ ភាសា សាសនា ជនជាតិដើម អាយុ ឬពិការភាព លុបបំបាត់រាល់ទម្រង់នៃការរើសអើង ទាំងអស់" ។[31]

(II) សិទ្ធិទទួលការអប់រំរបស់ប្រជាពលរដ្ឋ ជាប្រជាជនភាគតិច និងជនជាតិដើមភាគតិច ត្រូវតែគោរពអោយបានពេញលេញ[32] ដោយអនុលោមតាម :

- *អនុវត្តសិទ្ធិរៀនជាមាតុភាសា[33] និងសិទ្ធិប្រើប្រាស់វិធីសាស្ត្របង្រៀនសមស្របតាមលក្ខណៈវប្បធម៌ សម្រាប់ការផ្តល់ និងផ្ទេរចំណេះដឹង។[34]*

- *ការបង្រៀន មិនត្រឹមតែបង្រៀនមាតុភាសា និងដោយប្រើមាតុភាសាទេ ប៉ុន្តែការបង្រៀនភាសាជាតិ ឬភាសាផ្លូវការ និងភាសាសកល សម្រាប់ការប្រាស្រ័យទាក់ទង អាចផ្តល់ឱកាសអោយប្រជាជនភាគតិច និងជនជាតិដើមភាគតិច ចូលរួម និងរួមចំណែកដល់សហគមន៍ និងសង្គមទាំងមូល។[35]*

(III) ការអប់រំ គួរលើកកំពស់ការយល់ដឹង និងផ្សព្វផ្សាយចំណេះដឹង អំពីតម្លៃ នៃនានាភាព និងពហុភាពនៃវប្បធម៌ (ភាសា)[36] ហើយក្នុងន័យនេះ ត្រូវពិចារណាថា :

- *"កម្មវិធីសិក្សាតាមសាលា (គួរកែប្រែអោយស្របតាមតម្រូវការ) ដើម្បីលើកកំពស់ និង ពង្រីកការដាក់ បញ្ចូលប្រវត្តិសាស្ត្រ វប្បធម៌ ភាសា និងអត្តសញ្ញាណរបស់ប្រជាជនភាគតិច និងជនជាតិដើមភាគតិច ទៅក្នុងកម្មវិធីសិក្សា"។[37]*

- *វប្បធម៌នៃការបង្រៀន និងរៀនភាសា គួរតែពង្រីង និងពង្រីកអោយបានទូលំទូលាយ ដើម្បី ស្វែងយល់អោយ បានច្រើនអំពីវប្បធម៌[38] ហើយ "ភាសាមិនគួរចាត់ទុកជាលំហាត់ ឬការសិក្សាបែបសាមញ្ញទេ ប៉ុន្តែភាសា គួរចាត់ទុកជាឱកាសដ៏ប្រសើរ សម្រាប់យកទៅប្រើ ដើម្បីស្វែងយល់អំពីជីវិត អក្សរសាស្ត្រ អក្សរលិល្ប៍ និងទំនៀមទម្លាប់"។[39]*

# កំណត់សម្គាល់

1. cf. Wurm, S. (Ed.) (2001): Atlas of the World's Languages in Danger of Disappearing, Paris, UNESCO Publishing.

2. cf. Grimes, B. (Ed.) (2000): Ethnologue: Languages of the World, 14th Edition, Dallas, Texas, SIL International.

3. cf. លទ្ធផលរកឃើញ ពីការស្រាវជ្រាវពិស្តារ សម្រាប់ធនាគារពិភពលោក : Dutcher, N. សហការជាមួយ Tucker, G.R. (1997): ការប្រើប្រាស់ភាសាទីមួយ និងភាសាទីពីរ នៅក្នុងវិស័យអប់រំ : ការពិនិត្យ និងវិភាគ បទពិសោធអប់រំ Washington D.C., World Bank, Country Department III: ការសន្និដ្ឋានដ៏សំខាន់បំផុត ទទួលបានពីការស្រាវជ្រាវ និងបទពិសាធ ដែលបានសរសេរនៅក្នុងឯកសារការងារនេះគឺថា នៅពេលការរៀនសូត្រ គឺជាគោលដៅ គិតទាំងការរៀនភាសាទីពីរ ភាសាទីមួយរបស់កុមារ (ឧទាហរណ៍ មាតុភាសារបស់កុមារ) គួរប្រើក្នុងកម្រិត សមរម្យសម្រាប់ការរៀន និងបង្រៀន តាំងពីចូលរៀននៅវ័យកុមារតូច។ ភាសាទីមួយមានសារៈសំខាន់ សម្រាប់ការបង្រៀនអំពីរៀនអាន និងសម្រាប់អោយសិស្សស្វែងយល់អំពីមុខវិជ្ជារៀននៅក្នុងសាលា។ ដូច្នេះ មូលដ្ឋានគ្រឹះដ៏សំខាន់ សម្រាប់លើកកំពស់ និងបង្កើនចំណេះដឹងអំពី ភាសាទីពីរ គឺអស្រ័យលើការយល់ដឹងច្បាស់អំពីភាសាទីមួយ។ cf. also Mehrotra, S. (1998): ការអប់រំសម្រាប់ទាំងអស់គ្នា : មេរៀន និងបទពិសោធ ពីគោលនយោបាយទទួលបានពីប្រទេស ដែលសម្រេចលទ្ធផលច្រើន។ ឯកសារការងាររបស់អង្គការ UNICEF : "ក្នុងស្ថានភាព ដែលមាតាបិតាសិស្សជាអនក្ខរជន ប្រសិនបើ ការរៀន និងបង្រៀននៅសាលា ប្រើភាសាមួយ ដែលនិយាយនៅក្នុងគ្រួសារ បញ្ហាដែលសិស្សជួយប្រទះក្នុងបរិយាកាសសិក្សាបែបនេះគឺ បញ្ហានៃភាពក្រីក្រ ហើយឱកាសបោះបង់ចោលការសិក្សាក៏មានខ្ពស់ដែរ។ នៅក្នុងស្ថានភាពបែបនេះ បទពិសោធទទួលបានពីប្រទេស ដែលសម្រេចលទ្ធផលច្រើន គឺជាគំរូដ៏ច្បាស់លាស់ : មាតុភាសា ត្រូវប្រើជាមធ្យមនៅក្នុងការរៀន និងបង្រៀននៅកម្រិតបឋមសិក្សាក្នុងគ្រប់ករណីទាំងអស់។ ការស្រាវជ្រាវជាច្រើន បានបង្ហាញថា សិស្សរៀនអាន ជាមាតុភាសាបានលឿន ប្រសិនបើបង្រៀនជាមាតុភាសា។ ទីពីរ សិស្សដែលធ្លាប់បានរៀនជាមាតុភាសា រៀនអានភាសាទីពីរលឿនជាងសិស្ស ដែលចាប់ផ្តើមរៀនភាសាទីពីរ ដោយមិនបានរៀនមាតុភាសាជាមុន។ ទីបី ប្រសិនបើនិយាយ អំពីជំនាញរៀននៅសាលា សិស្សដែល រៀនអានជាមាតុភាសា នឹងទទួលបានជំនាញរៀននៅសាលាលឿនជាងសិស្ស ដែលមិនបានរៀនអានជាមាតុភាសាមុន"។ cf. also Dutcher, N: Expanding Educational Opportunity in Linguistically Diverse Societies, Center for Applied Linguistics, Washington DC.(2001)

4. cf. Hamburg Declaration on Adult Learning UNESCO (1997); សេចក្តីថ្លែងការណ៍ ស្តីពីសិទ្ធិពលរដ្ឋ ជាពលរដ្ឋជនជាតិដើមភាគតិច ក្រុមសាសនា និងជនជាតិភាគតិចគិតតាមក្រុមប្រើភាសាផ្សេង (១៩៩២)។ អនុសញ្ញា និងអនុសាសន៍ប្រឆាំងនឹងការរើសអើងនៅក្នុងការអប់រំ (១៩៦០)។ ១៨ គ/សេចក្តីសម្រេចលេខ ១.៤១ : កិច្ចសហការជាមួយអង្គការក្រៅរដ្ឋាភិបាល អន្តរជាតិ បំពេញបេសកកម្មក្នុងវិស័យអប់រំ (១៩៧៤)។ cf. also Chapter III: UNESCO Guidelines on Language and Education, Principle III.

5. cf. អនុសញ្ញាអន្តរជាតិស្តីពីការការពារសិទ្ធិរបស់ពលករជាជនអន្តោប្រវេសន៍ និងសមាជិកគ្រួសារពលករជាជនអន្តោប្រវេសន៍ (១៩៩០)។

6. ៣០គ/សេចក្តីសម្រេចលេខ១២ : ការអនុវត្តគោលនយោបាយភាសា សម្រាប់ពិភពលោក ដោយអាស្រ័យលើការប្រើប្រាស់ពហុភាសា (១៩៩៩) អង្គការយូណេស្កូ។

**7.** លើសពីនេះទៀត មានកិច្ចព្រមព្រៀង និងអនុសាសន៍ជាច្រើន ដែលអាចប្រើជាឯកសារជំនួយស្មារតី ស្តីពីការប្រើភាសា និងការអប់រំ ដូចជា (cf. the Durban Statement of Commitment, Seventh Conference of Ministers of Education of African Member States 1998; Harare Declaration, Intergovernmental Conference of Ministers on Language Policy in Africa 1997; Final Report Seventh Conference of Ministers of Education of Latin America and the Caribbean, Kingston, 1996)

**8.** cf. International Conference on Education 46th Session 2001: Final Report, p.11: "របាយការណ៍នេះ បង្ហាញយ៉ាងច្បាស់ថា ភាសាប្រើសម្រាប់ការរៀន និងបង្រៀន ត្រូវតែប្រើនៅពេលសិស្សចាប់ផ្តើមចូលរៀន។ ការចាប់ផ្តើមរៀនភាសាតាំងពីដំបូង គឺជាដើមទុនសម្រាប់ការរៀននៅពេលអនាគត។ ភាសា ដែលត្រូវរៀនដំបូងគឺមាតុភាសា"។

**9.** cf. សន្និសីទអន្តរជាតិស្តីពីការអប់រំលើកទី៤៦ ឆ្នាំ ២០០១ : របាយការណ៍បញ្ចប់ ទំព័រ ១៧ : ខ្លឹមសារមេរៀននៅក្នុងកម្មវិធីអប់រំ ត្រូវឆ្លុះបញ្ចាំងអំពី "សារៈសំខាន់នៃតួនាទីរបស់ការប្រាស្រ័យទាក់ទង ការបញ្ចេញមតិយោបល់ និងសមត្ថភាពស្តាប់ និងពិភាក្សា ជាដំបូងដោយប្រើមាតុភាសា បន្ទាប់មកប្រើភាសាផ្លូវការបន្ទាប់មកទៀត ប្រើភាសាបរទេសមួយឬពីរទៀត។" សន្និសីទអន្តរជាតិ ស្តីពីការអប់រំលើកទី៤៣ ឆ្នាំ ១៩៩២ : របាយការណ៍បញ្ចប់ ទំព័រ២០ : "នៅពេលជ្រើសរើសយក ភាសាមួយមកប្រើសម្រាប់ការរៀន និងបង្រៀន ជាពិសេសនៅកម្រិតអប់រំមូលដ្ឋាន ត្រូវពិចារណា ទៅលើលក្ខខណ្ឌពីរ ប្រសិទ្ធភាពនៃសកម្មភាពរៀន និងបង្រៀន និងសិទ្ធិរបស់ពលរដ្ឋ និងសិទ្ធិរបស់ក្រុមជនជាតិភាគតិច ដែលត្រូវថែរក្សាអត្តសញ្ញាណវប្បធម៌ ដែលក្នុងអត្តសញ្ញាណវប្បធម៌នោះ គឺភាសាជាយានដ៏សំខាន់។"

**10.** cf. សន្និសីទអន្តរជាតិស្តីពីការអប់រំលើកទី៤៦ ឆ្នាំ ២០០១ : របាយការណ៍បញ្ចប់ ទំព័រ ១១ : "ការរៀនភាសាគឺជាកត្តាគន្លឹះសម្រាប់រស់នៅរួមគ្នា"។ សន្និសីទអន្តរជាតិស្តីពីការអប់រំលើកទី ៤៤ ឆ្នាំ ១៩៩៤ : របាយការណ៍បញ្ចប់ ទំព័រ២៦ : "ការរៀនភាសាបរទេស ផ្តល់មធ្យោបាយមួយសម្រាប់លើកកំពស់ការយល់ដឹងអំពីវប្បធម៌ផ្សេងដែលជាមូលដ្ឋានគ្រឹះ សម្រាប់លើកកំពស់ការយល់គ្នា រវាងសហគមន៍ និងសហគមន៍ និងរវាងប្រទេស និងប្រទេស"។

**11.** cf. សន្និសីទអន្តរជាតិស្តីពីការអប់រំលើកទី៤៦ ឆ្នាំ ២០០១ : របាយការណ៍បញ្ចប់ : វេទិកាអប់រំពិភពលោកឆ្នាំ២០០០ : របាយការណ៍បញ្ចប់ : សេចក្តីថ្លែងការណ៍ក្រុងដេលី និងក្របខ័ណ្ឌ សកម្មភាព។ សន្និសីទកំពូលស្តីពីការអប់រំសម្រាប់ទាំងអស់គ្នាឆ្នាំ ១៩៩៣ : ការប្រើភាសាក្នុងស្រុក នៅក្នុងវិស័យអប់រំ អង្គការយូណេស្កូ ទីក្រុងភារីស ឆ្នាំ ១៩៥៣។

**12.** cf. សេចក្តីថ្លែងការណ៍ក្រុង Amman *(១៩៩៦)* : "តួនាទីដ៏សំខាន់របស់មាតុភាសា សម្រាប់ ការរៀន និងបង្រៀន" ត្រូវតែទទួលស្គាល់ជាផ្លូវការ។ សេចក្តីថ្លែងការណ៍ក្រុងដេលី និងក្របខ័ណ្ឌសកម្មភាព សន្និសីទកំពូលស្តីពីការអប់រំសម្រាប់ទាំងអស់គ្នា *(១៩៩៣)*។ "នៅពេលដែលភាសាសម្រាប់រៀន និងបង្រៀន មិនមែនជាមាតុភាសារបស់អ្នករៀន លទ្ធផលសិក្សា និងសកម្មភាពរៀនរបស់សិស្ស ហាក់ដូចជាមិនសូវល្អ ហើយយឺតយ៉ាវទៀត។ ដោយសារហេតុផលនេះ អ្នកជំនាញអប់រំ បានតស៊ូមតិ ដើម្បីគាំទ្រ ដល់ផលប្រយោជន៍ទទួលបានពីការរៀន និងបង្រៀន ដោយប្រើមាតុភាសា ប្រសិនបើអាចធ្វើបាន។

**13.** cf. សន្និសីទអន្តរជាតិស្តីពីការអប់រំលើកទី៤២ ឆ្នាំ ១៩៩០ : របាយការណ៍បញ្ចប់ : "នៅក្នុងស្ថានភាពប្រើពហុភាសា គោលនយោបាយទាក់ទងនឹងការប្រើភាសាសម្រាប់រៀនអក្ខរកម្ម ត្រូវតែតាក់តែងអោយបានប្រុងប្រយ័ត្ន ជាពិសេស នៅពេលដែលភាសាជាតិ ឬភាសាផ្លូវការខុសពីភាសាអ្នកស្រុកប្រើប្រាស់ប្រចាំថ្ងៃ។ ប្រើប្រាស់មាតុភាសា គឺជាការប្រសើរបំផុត"។

**14.** ការប្រើប្រាស់ភាសាក្នុងស្រុកនៅក្នុងការអប់រំ ទំព័រ៣៥ អង្គការយូណេស្កូ ក្រុងប៉ារីស *(១៩៥៣)*

**15.** idem, p.68.

**16.** idem, p.69.

**17.** idem, p.51.

**18.** idem, p.51.

**19.** idem, p.69.

**20.** cf. សន្និសីទអន្តរជាតិស្តីពីការអប់រំឆ្នាំ ១៩៩២ : "ការរៀបចំឯកសារបង្រៀន ជាមាតុភាសា ត្រូវតែបំផុស និង ពង្រឹងបន្ថែមអោយបានខ្លាំងក្លា" របាយការណ៍បញ្ចប់ ទំព័រ ២១។

**21.** អនុសាសន៍ពាក់ព័ន្ធនឹងកម្រិតស្ថានភាពនៃគ្រូបង្រៀនអនុម័ត ដោយសន្និសីទអន្តររដ្ឋាភិបាល ពិសេសស្តីពីកម្រិតស្ថានភាពនៃគ្រូបង្រៀន ឆ្នាំ ១៩៦៦។

**22.** ៣០ គ/សេចក្តីសម្រេចលេខ៤២ : ឈានទៅរកវប្បធម៌សន្តិភាព (១៩៩៩)។ ៣០ គ/សេចក្តីសម្រេចលេខ១២ : ការអនុវត្តគោលនយោបាយភាសា សម្រាប់ពិភពលោក សំអាងលើការប្រើប្រើនភាសា (១៩៩៩) អង្គការយូណេស្កូ។

**23.** សន្និសីទអន្តរជាតិស្តីពីការអប់រំឆ្នាំ ២០០១ គម្រោងស្នើសុំថវិកា ដើម្បីអនុវត្តសកម្មភាព (កថាខ័ណ្ឌ១៨)

**24.** ៣០ គ/សេចក្តីសម្រេចលេខ១២ : ការអនុវត្តគោលនយោបាយភាសា សម្រាប់ពិភពលោក សំអាងលើការប្រើប្រើនភាសា (១៩៩៩) អង្គការយូណេស្កូ។

**25.** ការប្រើភាសាក្នុងស្រុកនៅក្នុងការអប់រំ អង្គការយូណេស្កូ ក្រុងប៉ារីស (១៩៥៣)

**26.** idem, p.69.

**27.** idem, p.69.

**28.** ៣០ គ/សេចក្តីសម្រេចលេខ១២ : ការអនុវត្តគោលនយោបាយភាសា សម្រាប់ពិភពលោក សំអាងលើការប្រើប្រើនភាសា (១៩៩៩) អង្គការយូណេស្កូ។

**29.** ៣០ គ/សេចក្តីសម្រេចលេខ១២ : ការអនុវត្តគោលនយោបាយភាសា សម្រាប់ពិភពលោក សំអាងលើការប្រើប្រើនភាសា (១៩៩៩) អង្គការយូណេស្កូ។

**30.** ពង្រាងអនុសាសន៍ពាក់ព័ន្ធនឹងការលើកកំពស់ និងការប្រើពហុភាសា និងឱកាសប្រើប្រព័ន្ធអ៊ិនធឺណេតជាសកល (កថាខ័ណ្ឌ១) (កំណត់សម្គាល់ : ដោយមានសំណូមពរពីមហាសន្និសីទ ឆ្នាំ ២០០១ សេចក្តីសម្រេច ៣០ គ/សេចក្តីសម្រេចលេខ៣៣។ ពង្រាងអនុសាសន៍នេះ នឹងដាក់ជូនគណៈកម្មាធិការនាយកប្រតិបត្តិនៅក្នុងសន្និសីទលើកទី ១៦៥)

**31.** សេចក្តីថ្លែងការណ៍ក្រុងប៉េកាំង និងក្របខ័ណ្ឌសកម្មភាព (១៩៩៥) និងអានបន្ថែម អនុសញ្ញា និង អនុសាសន៍ប្រឆាំងនឹងការរើសអើងក្នុងការអប់រំ (១៩៦០) មាត្រា១ : "ពាក្យរើសអើង" មាន វិសាលភាពលើការបែងចែក ការមិនរាប់បញ្ចូល ការកំណត់ព្រំដែន ឬការចូលចិត្តពេញនិយម អាស្រ័យលើ ជាតិសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា ទស្សនៈនយោបាយ ឬទស្សនៈផ្សេងៗ ដើមកំណើត ស្ថានភាពសេដ្ឋកិច្ច ឬកំណើត ដែលមានគោលបំណងបង្កអោយបាត់ បង់សមភាព នៅក្នុងការអប់រំ"។

**32.** ២៨ គ/សេចក្តីសម្រេចលេខ១៥.៤ : សេចក្តីថ្លែងការណ៍ និងក្របខ័ណ្ឌសកម្មភាពស្តីពីការអប់រំ ដើម្បីសន្តិភាព សិទ្ធិមនុស្ស និងប្រជាធិបតេយ្យ (១៩៩៥) អង្គការយូណេស្កូ។

**33.** សេចក្តីថ្លែងការណ៍ក្រុងហាំបឺក ស្តីពីការរៀនសូត្ររបស់មនុស្សពេញវ័យ សន្និសីទអន្តរជាតិលើក ទី៥ ស្តីពីការអប់រំមនុស្សពេញវ័យ ឆ្នាំ ១៩៩៧ មាត្រា ១៥។ អនុសញ្ញាអង្គការពលកម្មអន្តរជាតិលេខ ១៦៩ ស្តីពីជនជាតិដើមភាគតិច និងជនជាតិភាគតិចតំបន់ភ្នំ រស់នៅក្នុងប្រទេសឯករាជ្យ (១៩៨៩) ចែងថា "កុមារកូនជនជាតិដើមភាគតិច និងកូនជនជាតិភាគតិចតំបន់ភ្នំ ត្រូវមានឱកាសអនុវត្ត រៀនអាន និងរៀនសរសេរមាតុភាសាជនជាតិដើមភាគតិច ឬភាសាជនជាតិដើមភាគតិច និង ជនជាតិភាគតិចនិយមប្រើបំផុត" (មាត្រា២៨.១)។ សេចក្តីថ្លែងការណ៍ ស្តីពីសិទ្ធិពលរដ្ឋ ជាជនជាតិ ដើមភាគតិច ឬជនជាតិភាគតិច ក្រុមសាសនា និងក្រុមជនជាតិ

ភាគតិចប្រើភាសាផ្សេង (១៩៩២) សំណូមពរអោយរដ្ឋទាំងអស់ "ចាត់វិធានការ តាមលទ្ធភាពដែលអាចធ្វើបាន ដើម្បីធានាអោយប្រជាជនភាគតិចមានឱកាសគ្រប់គ្រាន់ ដើម្បីរៀនមាតុភាសា ឬរៀន និងបង្រៀនជាមាតុភាសា" (មាត្រា៤.៣)។

**34.** សេចក្តីថ្លែងការណ៍សកលរបស់អង្គការយូណេស្កូ ស្តីពីនានាភាពនៃវប្បធម៌ (២០០១) ផែនការសកម្មភាពកថាខ័ណ្ឌ៨។

**35.** cf. អនុសញ្ញា និងអនុសាសន៍ប្រឆាំងនឹងការរើសអើងក្នុងការអប់រំ (១៩៦០) មាត្រា៥ : "សមាជិកនៃក្រុមប្រជាជន ភាគតិច (មិនគួរហាមឃាត់) មិនអោយស្វែងយល់អំពីវប្បធម៌ និងភាសារបស់សហគមន៍ទាំងមូលទេ" ១៨ គ/សេចក្តីសម្រេចលេខ១.៤១ : កិច្ចសហការជាមួយ អង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ ធ្វើការនៅក្នុងវិស័យអប់រំ ឆ្នាំ ១៩៧៤ អង្គការយូណេស្កូ។ មនុស្ស គ្រប់ៗរូបមានសិទ្ធិ ទទួលចំណេះដឹងអំពីមាតុភាសារបស់ខ្លួន និងមានសិទ្ធិទទួល ចំណេះដឹងនៃភាសាផ្សេងទៀត ដូចជា ភាសាអន្តរជាតិ ដែលអាចធានាអោយមនុស្សនោះ មានសមត្ថភាពស្វែងយល់ អំពីវប្បធម៌ជាតិ និងមានឱកាសស្វែងយល់អំពីវប្បធម៌ពិភពលោក និងមានសមត្ថភាពផ្លាស់ និងចែករំលែកចំណេះដឹង ជាមួយមនុស្សដទៃ។ អនុសញ្ញាអង្គការពលកម្មអន្តរជាតិលេខ១៦៩ ស្តីពីជនជាតិដើមភាគតិច និងជនជាតិភាគតិចតំបន់ភ្នំ នៅប្រទេសឯករាជ្យ (១៩៨៩)។ ចាត់វិធានការអោយបានគ្រប់គ្រាន់ ដើម្បីធានាថា ប្រជាជនភាគតិចទាំងនេះ មានឱកាសរៀនភាសាជាតិ ឬភាសា ផ្លូវការមួយរបស់ខ្លួន អោយស្ទាត់ជំនាញ (មាត្រា២៨.២)។ នានាភាពតាមការច្នៃប្រឌិតរបស់យើង : របាយការណ៍របស់គណៈកម្មការពិភពលោក ស្តីពីវប្បធម៌ និងអភិវឌ្ឍន៍ (១៩៩៥) អង្គការយូណេស្កូ។ សាលារៀនគួរបង្រៀនភាសាអោយច្រើន ជាពិសេស ភាសាក្នុងស្រុក (ភាសាជនជាតិភាគតិច) និងភាសាជនជាតិភាគច្រើន ទំព័រ៥៩។

**36.** UNESCO Universal Declaration on Cultural Diversity (2001), Action Plan, para 7.

**37.** សន្និសីទអន្តរជាតិលើកទី៥ ស្តីពីការអប់រំមនុស្សពេញវ័យ ឆ្នាំ១៩៩៧ : របាយការណ៍សិក្ខាសាលា : ជនជាតិភាគតិច និងការរៀនសូត្ររបស់មនុស្សពេញវ័យ។ សេចក្តីថ្លែងការណ៍ស្តីពីសិទ្ធិពលរដ្ឋ ជនជាតិដើមភាគតិច ប្រជាជនភាគតិច សិទ្ធិសាសនា និងសិទ្ធិជនជាតិភាគតិចប្រើភាសាផ្សេង (១៩៩២) : មាត្រា៤.៤ : "ចាត់វិធានការអនុវត្តសកម្មភាពក្នុង វិស័យអប់រំ ដើម្បីបំផុស និងលើកកំពស់ចំណេះដឹងអំពីភាសា និងវប្បធម៌របស់ជនជាតិភាគតិច។" នានាភាពតាមការ ច្នៃប្រឌិត របស់យើង : របាយការណ៍របស់គណៈកម្មការពិភពលោក ស្តីពីវប្បធម៌ និងអភិវឌ្ឍន៍ (១៩៩៥) ទំព័រ ៦០ អង្គការយូណេស្កូ។ វប្បធម៌របស់ជនជាតិភាគតិច (ឬជនជាតិដើមភាគតិច) គួរមានកន្លែង ប្រសើរមួយ មិនត្រឹមតែ នៅក្នុងប្រព័ន្ធអប់រំប៉ុណ្ណោះទេ ប៉ុន្តែនៅក្នុងរូបភាពនៃ"វប្បធម៌ជាតិ"។

**38.** ២៨ គ/សេចក្តីសម្រេចលេខ១៥.៤ : សេចក្តីថ្លែងការណ៍ និងក្របខ័ណ្ឌសកម្មភាពរួមស្តីពីការអប់រំ ដើម្បីសន្តិភាព សិទ្ធិមនុស្ស និងប្រជាធិបតេយ្យ (១៩៩៥) អង្គការយូណេស្កូ មាត្រា ១៩ : "ការរៀន ភាសាបរទេស ទទួលបានឱកាស និងមធ្យោបាយដើម្បីស្វែងយល់អំពីវប្បធម៌ផ្សេងៗ ឬស្វែងយល់កាន់តែប្រសើរ រវាងសហគមន៍ និងសហគមន៍ និង រវាងប្រទេស និងប្រទេស។"

**39.** Our Creative Diversity: Report of the World Commission on Culture and Development (1995), UNESCO, p.168.

អង្គការយូណេស្កូមានតួនាទីដ៏សំខាន់មួយ ក្នុងការផ្តល់ក្របខ័ណ្ឌសកម្មភាពអន្តរជាតិសម្រាប់ការតាក់តែង គោលនយោបាយអប់រំ និងការអនុវត្តគោលនយោបាយអប់រំ ដើម្បីដោះស្រាយបញ្ហាគន្លឹះៗ និងស្មុគ្រស្មាញនៅក្នុងវិស័យអប់រំ។ ជាពិសេស ជម្រើសនៃការប្រើភាសាក្នុងការរៀន និងបង្រៀន នៅក្នុងប្រព័ន្ធអប់រំ គឺជាលក្ខខណ្ឌ ឬជាក្តីកង្វល់មួយ ហើយជម្រើសនេះគឺជាបញ្ហាដែលមានគំនិតផ្ទុយគ្នាច្រើន ហើយពិបាកនឹងសម្រេចថា ត្រូវជ្រើសរើសយកជំហរមួយណា។ ចម្ងល់ទាក់ទងនឹងអត្តសញ្ញាណជាតិ និងអំណាចមានអន្តរទំនាក់ទំនងស្អិតរមួតទៅនឹងការប្រើប្រាស់ភាសានៅក្នុងថ្នាក់រៀន។ ភាសា មានជីវិតរស់រវើក ហើយមានបំរែបំរួល និងផ្លាស់ប្តូរឥតឈប់ ដែលមានឥទ្ធិពលទៅលើការប្រាស្រ័យទាក់ទងគ្នានៅក្នុងសង្គមផ្សេងៗគ្នា។ អ្នកតាក់តែងគោលនយោបាយអប់រំមានការលំបាកក្នុងការសម្រេចចិត្តទាក់ទងនឹងការប្រើប្រាស់ភាសា ការរៀនសូត្រ និងអំពីកម្មវិធីសិក្សានៅក្នុងសាលា ព្រោះការសម្រេចចិត្តនេះ អាចជាន់គ្នា រវាងបច្ចេកទេស និងនយោបាយ។

ប្រសិនបើមានការពេញនិយមក្នុងការប្រើមាតុភាសា (ភាសាទីមួយ) នៅក្នុងការរៀន និងបង្រៀន ចាំបាច់ត្រូវថ្លឹងថ្លែងអំពីសមត្ថភាពរបស់អ្នករៀន ក្នុងការប្រើប្រាស់ភាសាក្នុងស្រុកក្នុងការរៀនសូត្រ និងផ្តល់លទ្ធភាព និងឱកាសអោយអ្នករៀន មានសមត្ថភាពប្រើភាសាសកលក្នុងការប្រាស្រ័យ ទាក់ទង តាមរយៈប្រព័ន្ធអប់រំផងដែរ។ គោលបំណងរបស់ឯកសារនេះ គឺសំដៅពិចារណាអំពីបញ្ហាមួយចំនួន ទាក់ទងនឹងភាសា និងការអប់រំ ហើយសំដៅផ្តល់សេចក្តីណែនាំ និងគោលការណ៍ពាក់ព័ន្ធមួយចំនួន។ ដើម្បីសម្រេចគោលបំណងនេះ យើងត្រូវយល់ច្បាស់អំពីគោលនយោបាយភាសាប្រើប្រាស់នៅក្នុងវិស័យអប់រំ ជាពិសេសនៅក្នុងបរិបទនៃការអប់រំសម្រាប់ទាំងអស់គ្នា និងស្របតាម គោលដៅក្រុងដាកា ដែលធានាថា នៅមុន ឬត្រឹមឆ្នាំ ២០១៥ កុមារទាំងអស់ នឹងមានឱកាសទទួលបានការអប់រំបឋមសិក្សា ប្រកបដោយគុណភាពគ្រប់ៗគ្នា ហើយធានាថា នៅមុន ឬត្រឹមឆ្នាំ ២០១៥ អក្ខរកម្មមនុស្សចាស់ នឹងកើនបាន ៥០ ភាគរយ។

→ Education in a multilingual world

_UNESCO Education Position Paper_